# បច្ចេកទេសចិញ្ចឹមត្រី ជាលក្ខណៈគ្រួសារ




ប្រភពធនធានចំរុះសំរាប់ចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
កន្ទក់ ចុងអង្ករ
លាមកសត្វ
រណ្តៅជីកំប៉ុស
កាកសំណល់បន្លែ
ម្ទេស

# បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ



ខែ កក្កដា ឆ្នាំ ២០១១

# មាតិការអត្ថបទ

**សេចក្តីផ្តើម**.........................................................................................................-១-

## ផ្នែកទី ១ : បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះ

ផលប្រយោជន៍នៃការចិញ្ចឹមត្រី.......................................................................................-៣-
ប្រភពធនធាននៃការចិញ្ចឹមត្រី.......................................................................................-៤-
**១. លក្ខណៈស្រះ**.........................................................................................................-៤-
ក. ការជ្រើសរើសទីតាំងជីកស្រះ.......................................................................................-៤-
ខ. លក្ខណៈស្រះចិញ្ចឹមត្រី.......................................................................................-៥-
គ. របៀបជីកស្រះ.......................................................................................-៦-
**២. ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម**.......................................................................................-៨-
ក. ការប្រើប្រាស់កំបោរ.......................................................................................-៨-
ខ. ការប្រើប្រាប់ជី.......................................................................................-៩-
គ. ការរៀបចំស្រះ.......................................................................................-១៣-

**៣. ការដាក់កូនត្រីចិញ្ចឹម**..........-១៤-
ក. ប្រភេទត្រីជ្រើសរើសដាក់ចិញ្ចឹម..........-១៤-
ខ. ចំនួន និងទំហំកូនត្រីដាក់ចិញ្ចឹម..........-១៩-
គ. ពេលវេលាដាក់កូនត្រីចិញ្ចឹម..........-២១-
ឃ. ការដឹកជញ្ជូនកូនត្រី..........-២១-
ង. របៀបលែងកូនត្រី..........-២៣-
**៤. ការដាក់ជីបន្ថែមក្រោយពេលដាក់ត្រីចិញ្ចឹម**..........-២៤-
ក. ជីធម្មជាតិ..........-២៤-
ខ. ជីគីមី..........-២៥-
**៥. ការផ្តល់ចំណី**..........-២៦-
ក. ប្រភេទចំណី..........-២៦-
ខ. ការផ្តល់ចំណី..........២៦-
**៦. ការគ្រប់គ្រងស្រះចិញ្ចឹមត្រី**..........-២៩-
**៧. ការប្រមូលផល**..........-៣២-

ក. ការប្រមូលផលរំលស់..........-៣២-
ខ. ការប្រមូលផលទាំងស្រុង..........-៣៤-
**៨. ការកត់ត្រាចំណាយ និងចំណូល**..........-៣៥-
**៩. កត្តាសំខាន់ៗដែលធ្វើឱ្យការចិញ្ចឹមកូនត្រីទទួលជោគជ័យ**..........-៣៦-

## ផ្នែកទី ២ : បច្ចេកទេសចិញ្ចឹមកូនត្រីក្នុងស្រែ

ផលប្រយោជន៍នៃការចិញ្ចឹមត្រីក្នុងស្រែ..........-៣៨-
ប្រភពធនធានសម្រាប់ចិញ្ចឹមត្រីក្នុងស្រែ..........-៣៩-
**១. លក្ខណៈស្រែ**..........-៤០-
ក. ការជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រី..........-៤០-
ខ. លក្ខណៈស្រែចិញ្ចឹមត្រី..........-៤០-
គ. របៀបជីកជម្រកត្រីក្នុងស្រែ..........-៤១-

**២. ការរៀបចំស្រែមុនដាក់ត្រីចិញ្ចឹម**........................................-៤៦-
ក. ការប្រើប្រាស់កំបោរ........................................-៤៦-
ខ. ការប្រើប្រាស់ជី........................................-៤៧-
គ. ការរៀបចំស្រែមុនពេលដាក់កូនត្រីចិញ្ចឹម........................................-៤៧-
**៣. ការដាក់ត្រីចិញ្ចឹម**........................................-៤៩-
ក. ប្រភេទត្រីជ្រើសរើសដាក់ចិញ្ចឹម........................................-៤៩-
ខ. ចំនួន និងទំហំកូនត្រីដាក់ចិញ្ចឹម........................................-៥១-
គ. ពេលវេលាដាក់កូនត្រីចិញ្ចឹម........................................-៥២-
ឃ. ការដឹកជញ្ជូនកូនត្រី........................................-៥៣-
ង. របៀបលែងកូនត្រី........................................-៥៣-
**៤. ការដាក់ជីបន្ថែមក្រោយពេលដាក់ត្រីចិញ្ចឹម**........................................-៥៤-
**៥. ការផ្តល់ចំណី**........................................-៥៥-
**៦. ការគ្រប់គ្រងស្រែចិញ្ចឹមត្រី**........................................-៥៦-
**៧. ការប្រមូលផល**........................................-៥៦-
**៨. កត្តាសំខាន់ៗដែលត្រូវយកចិត្តទុកដាក់**........................................-៥៧-

# សេចក្តីផ្តើម

ប្រទេសកម្ពុជាសម្បូរធនធានមច្ឆាជាតិ ដែលមាននៅក្នុងទន្លេ ស្ទឹង បឹងបួរ ព្រែក អូរ ប្រឡាយ នានា។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ ដោយសារមានការប្រែប្រួលបរិស្ថានធម្មជាតិ និងកំណើនប្រជាជនបានធ្វើឱ្យតម្រូវការត្រីកាន់តែកើនឡើងជាលំដាប់ ហើយបរិមាណផលត្រីក្នុងធម្មជាតិមិនអាចផ្គត់ផ្គង់បានតាមតម្រូវការ។

ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាន និងកំពុងយកចិត្តទុកដាក់ផ្សព្វផ្សាយដល់ប្រជាកសិករ នូវវិធីសាស្ត្រគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទភាព នៅតាមគ្រប់តំបន់ដែនទឹកធម្មជាតិនៃព្រះរាជណាចក្រកម្ពុជា ដោយជួយរៀបចំបង្កើត ឱ្យមានសមាគមន៏គ្រប់គ្រងនៅតាមមូលដ្ឋានដើម្បីឱ្យប្រជាកសិកយល់ច្បាស់ពីតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងធនធានជលផល ក្នុងតំបន់របស់ខ្លួន ។ ក្រៅពីនេះរដ្ឋបាលជលផលសហការជាមួយគម្រោងនានា អនុវត្តការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ក្នុងគោលបំណង ដើម្បីធានាការផ្គត់ផ្គង់ម្ហូបអាហារទៅគ្រប់តំបន់ដែលប្រជាកសិករកំពុងទទួលការខ្វះខាតសាច់ត្រីទទួលទាន។ បច្ចុប្បន្នមានប្រជាកសិករជាច្រើនគ្រួសារបានទទួលការបណ្តុះបណ្តាល និងផ្សព្វផ្សាយ បច្ចេកទេសចិញ្ចឹមត្រីពីមន្ត្រីជំនាញនៃរដ្ឋាភិបាលជលផលសហការជាមួយបណ្តាអង្គការនានា និងដោយមានការចូលរួមផ្សព្វផ្សាយពីកសិករផងដែរនេះ ទាំងនេះបានធ្វើឱ្យពួកគាត់កំពុងមានសកម្មភាពចិញ្ចឹមត្រី និងឈានទៅផលិតកូនត្រីពូជនៅតាមតំបន់របស់ខ្លួនថែមទៀត។

ដើម្បីពង្រីកការងារផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មនេះ រដ្ឋបាលជលផល បានរៀបចំចងក្រងសៀវភៅស្ដីពី **(បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ)** នេះឡើងសំដៅជួយប្រជាកសិករនៅគ្រប់ទីកន្លែង ឱ្យចេះបច្ចេកទេសចិញ្ចឹមត្រី និងចូលរួមក្នុងសកម្មភាពចិញ្ចឹម ឱ្យបានផុសផុលទាំងអស់គ្នា ដើម្បីដោះស្រាយជីវភាពម្ហូបអាហារប្រចាំថ្ងៃ បង្កើនប្រាក់ចំណូល និងកាត់បន្ថយការចាប់ត្រីពីធម្មជាតិ ។



# ផ្នែកទី ១ : បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះ

## ផលប្រយោជន៍នៃការចិញ្ចឹមត្រី

- បង្កើតបានជាមុខរបរក្រៅពីការធ្វើស្រែ-ចំការ
- កាត់បន្ថយការចំណាយថវិការទិញត្រីពីផ្សារ
- តំរូវការសាច់ត្រីបានទាន់ពេលវេលា និងជាម្ហូបប្រចាំថ្ងៃ
- ផ្តល់ប្រូតេអ៊ីន និងសារធាតុចិញ្ចឹមល្អដល់សុខភាពមនុស្ស
- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- កាត់បន្ថយការនេសាទត្រីពីធម្មជាតិ
- បង្កើនផលត្រីធម្មជាតិក្នុងតំបន់
- កាត់បន្ថយការងារនៅឆ្ងាយពីផ្ទះ ។



*ជីវភាពគ្រួសារមុនពេលចិញ្ចឹមត្រី*



*ជីវភាពគ្រួសារក្រោយពេលចិញ្ចឹមត្រី*

# ប្រភពធនធានសម្រាប់ចិញ្ចឹមត្រី

- មានចំណេះដឹងក្នុងការចិញ្ចឹមត្រី
- មានកម្លាំងពលកម្មក្នុងការថែទាំក្នុងការចិញ្ចឹមត្រី
- មានស្រះជាប់ផ្ទះងាយស្រួលគ្រប់គ្រាងរយៈ ៦ ខែ
- មានកូនត្រីពូជដាក់ចិញ្ចឹម
- មានកាកសំណល់កសិដ្ឋាន ឬ ប្រភពធនធានកសិដ្ឋានច្រើនដូចជា ជីលាមកសត្វ និងកន្ទក់ជាដើម ។

## ១. លក្ខណៈស្រះ

ស្រះតូចធំអាចចិញ្ចឹមត្រីបានទាំងអស់ តែស្រះមានទំហំល្មមទើបងាយស្រួលក្នុងការគ្រប់គ្រង និងចិញ្ចឹមត្រីមានប្រសិទ្ធភាពខ្ពស់ ។

### ក. ការជ្រើសរើសទីតាំងជីកស្រះ

**ស្រះគួរជីកៈ**

- នៅជិតផ្ទះងាយស្រួលគ្រប់គ្រងបានគ្រប់ពេល
- ស្ថិតនៅទីវាលស្រឡះ
- ជិតប្រភពទឹក ( ប្រសិនបើមាន)



- ស្រះជាប់ស្រែកាន់តែប្រសើរ
- ស្រះគួរជីកនៅកន្លែងទំនាប មិនលិចទឹកនៅរដូវវស្សា ឬ លិចតិចតួច តែអាចលើកភ្លឺទប់បាន
- នៅទីកន្លែងដែលដីមានគុណភាពល្អ អាចរក្សាទឹកបានយូរ (លើកពី ៦ ខែ)
- នៅឆ្ងាយពីតំបន់ ដែលមានការប្រើប្រាស់ថ្នាំពុលកសិកម្មផ្សេងៗ ។

## ខ. លក្ខណៈស្រះចិញ្ចឹមត្រី

**ស្រះចិញ្ចឹមត្រីគួរៈ**

- ជីកមានរាងបួនជ្រុងទ្រវែង ដើម្បីងាយស្រួលគ្រប់គ្រង
- ស្រះមានទំហំប៉ុនណាក៏អាចចិញ្ចឹមបានដែរ តែគួមានទំហំពី ១០០ ម៉ែត្រការឡើងទៅ
- ស្រះមានទំហំពី ១០០ ម៉ែត្រការឡើងទៅសមស្របដល់ការចិញ្ចឹមត្រីបានធំធាត់
- ស្រះត្រូវមានជើងទេ (ជម្រាល) សមស្រប ដើម្បីការពារការហូរច្រោះ ឬ បាក់ដី
- ស្រះគួមានជម្រៅសមស្របពី ១.៥ ម៉ែត្រ ទៅ ២.៥ ម៉ែត្រ
- ស្រះត្រូវមានពន្លឺខ្ពស់ និងមាំល្អ ដើម្បីការពាទឹកលិច
- ដាំស្មៅនៅតាមពន្លឺស្រះ ដើម្បីកាត់បន្ថយការហូរច្រោះដែលធ្វើអោយទឹកល្អក់



❒ បាតស្រះត្រូវរាបស្មើរ ហើយមានជម្រាលទៅជ្រុងម្ខាង ងាយស្រួលពង្រើង និងប្រមូលផល

❒ នៅតាមភ្លឺស្រះគួរបង្កប់បំពង់ សម្រាប់បង្ហូរទឹកចូលស្រះ ។

## គ. របៀបជីកស្រះ

**ឧទាហរណ៏ :** បើជីកស្រះមានបណ្តោយ ១៥ ម៉ែត្រ X ទទឹង១០ ម៉ែត្រ X ជម្រៅ ២ ម៉ែត្រ ដំបូងត្រូវ :



❒ វាស់ចាប់ពីរបងផ្ទះ ឬ ក្បែរបងទុកយ៉ាងតិច ២ ម៉ែត្រ ដើម្បីទុកធ្វើភ្លឺស្រះ

❒ ទុកយ៉ាងតិចប្រវែង ១ ម៉ែត្រ ដើម្បីធ្វើចំណីភ្លឺ និងមាត់ស្រះ

❒ ចន្លោះពីមាត់ស្រះទៅជ្រុងនៃបាតស្រះមានប្រវែង ៦ ម៉ែត្រ ជាចន្លោះសម្រាប់ធ្វើជើងទេស្រះ

❒ អាចម៏ដីជីស្រះ ត្រូវយកមកធ្វើជាភ្លឺស្រះ ដោយបុកបង្ហាប់ឱ្យណែន

យើងចាប់ផ្តើមវាស់ចេញពីគ្រប់ជ្រុងស្រះ ( ទំហំ ១៥ ម៉ែត្រ X ១០ ម៉ែត្រ ) ប្រវែង ០.៧៥ ម៉ែត្រ ជុំវិញ ហើយជីកជម្រៅ០.៥ម៉ែត្រ បានស្រទាប់កាំទី ១ ហើយដីស្រទាប់មុខលើជម្រៅ ០.២ ម៉ែត្រ (២ តឹក) ត្រូវជីកយកអាចម៏ដីនេះទុកម្ញុំ ព្រោះជាដីមានជីជាតិសម្រាប់ក្រាលពីលើភ្លឺស្រះដាំស្មៅ ឬ ដំណាំផ្សេងៗ

❑ រួចវាស់ចេញពីស្រទាប់កាំទីមួយប្រវែង 0.៧៥ ម៉ែត្រ ទៀត និងជីកជម្រៅ 0.៥ ម៉ែត្រ ធ្វើយ៉ាងនេះរហូតបានចំនួន ៤ ស្រទាប់ សរុបជម្រៅ ២ ម៉ែត្រ និងមាន ៤ កាំនៅតាមជើងទេស្រះ

❑ បាតស្រះជីកហើយមានទំហំ ៩ ម៉ែត្រ X ៤ ម៉ែត្រ និងមានជញ្ជាំងស្រះជម្រាលល្អ ការពារការហូរច្រោះបាក់ដី



*ស្រះចោតមិនល្អសម្រាប់ចិញ្ចឹមត្រីទេ*



*ស្រះមានជើងទេរល្អសម្រាប់ចិញ្ចឹមត្រី*

❑ បន្ទាប់ពីជីចេញរាងស្រះហើយ យើងត្រូវយកស្រទាប់ដីខាងលើ ដែលយើងបានគរទុកមកចាក់នៅលើភ្លឺស្រះ ហើយបុកបង្ហាប់ និងចាប់ផ្ដើមដាំស្មៅនៅតាមខ្នងភ្លឺ ជើងភ្លឺ និងចំណើភ្លឺនៅមាត់ស្រះ

❑ នៅក្នុងភ្លឺស្រះត្រូវដាក់បង្កប់បំពង់បង្ហូរទឹកចូលស្រះឱ្យបានត្រឹមត្រូវ និងត្រូវដាក់ស្បែចងជាប់បំពង់បង្ហូរការពារកុំអោយសត្វផ្សេងៗចូលទៅក្នុងស្រះ ។





*ការដាំស្មៅនៅលើភ្លឺស្រះ*

## ២. ការរៀបចំស្រះមុនដាក់ត្រីចិញ្ចឹម

**ក. ការប្រើកំបោរ** ការប្រើប្រាស់កំបោរមានសារៈប្រយោជន៍ដូចខាងក្រោម៖

- ❒ ជួយកែលំអគុណភាពទឹក និងគុណភាពដីដែលមានជាតិជូរ
- ❒ សម្លាប់មេរោគ និងពពួកសត្វមួយចំនួនដែលស៊ីត្រី
- ❒ ធ្វើឱ្យកាកសំណល់ផ្សេងៗឆាប់រលួយ
- ❒ កាត់បន្ថយភាពល្អក់ទឹកស្រះ
- ❒ បន្ថែមសារជាតិចិញ្ចឹមដល់សត្វល្អិត និងបួងតុងរុក្ខជាតិ ។



*ការសំអាតស្រះដោយបាចកំបោរ*

**បរិមាណកំបោរត្រូវប្រើប្រាស់ ៖**

តាមធម្មតាស្រែ ១00 ម៉ែត្រការ៉េ ប្រើកំបោរពី ៥ ទៅ ១0 គីឡូក្រាម អាស្រ័យទៅនឹងភាពជាក់ស្តែងរបស់ទឹក និងដី។ ប្រសិនបើស្រែមានជាតិអាស៊ីតខ្លាំង ឬ កាកសំណល់ផ្សេងៗច្រើនកម្រិតកំបោរអាចច្រើនជាងនេះបន្តិច ។

**វិធីសាស្ត្រក្នុងការប្រើប្រាស់កំបោរ ៖**

យើងត្រូវចាក់កំបោរចូលទៅក្នុងធុងដែកឱ្យបានកន្លះធុង បន្ទាប់មកចាក់ទឹកចូលធុង។ ពេលចាក់ទឹកចូលធុងត្រូវប្រុងប្រយ័ត្ន ព្រោះកំបោរនៅពេលត្រូវទឹកវាចាប់ផ្តើមបញ្ចេញចំហាយក្តៅ។ បន្ទាប់ពីកំបោរបញ្ចេញអស់ចំហាយក្តៅ យើងយកកំណាត់ឈើកូទឹកកំបោរក្នុងធុងនោះ ហើយដួសបាចចូលទៅក្នុងផ្ទៃស្រែ ។

**ត្រូវប្រុងប្រយ័ត្ន នៅពេលប្រើកំបោរស ៖**

នៅពេលប្រើកំបោរដុំត្រូវតែប្រយ័ត្នប្រយែង ចៀសវាងប៉ះពាល់ផ្ទាល់នូវចំហាយកម្តៅដែលភាយចេញពីកំបោរប៉ះស្បែក និងភ្នែក។ ប្រសិនបើមានចូលភ្នែកត្រូវលាងសំអាតវាជាមួយនិងទឹកស្អាតឱ្យច្រើនភ្លាមៗ ហើយពិគ្រោះយោបល់ជាមួយគ្រូពេទ្យ ។

**ខ. ការប្រើជី៖**

ការប្រើជីមានន័យថា ការដាក់ជីទៅក្នុងស្រះត្រីនៅក្នុងពេលរៀបចំស្រះ។ ជាទូទៅជីលាមកសត្វ ឬ ជីគីមី ដូចជាជីអ៊ុយរ៉េ និងដេអាប៉េ ផ្តល់សារជាតិចិញ្ចឹម (អាសូត និងផូស្វ័រ) ទៅឱ្យរុក្ខជាតិ និងសត្វល្អិតបួងតុង ដែលជាចំណីធម្មជាតិសំខាន់សម្រាប់ការលូតលាស់របស់ត្រី។

**ជីលាមកមាន់ ៖** វាមានសាធាតុអាសូត និងផូស្វ័រច្រើនជាងជីលាមកសត្វផ្សេងៗទៀត។ ដូច្នេះ លាមកមាន់ជាជីល្អសម្រាប់ការចិញ្ចឹមត្រី។ ក្នុងពេលរៀបចំស្រះ យើងអាចដាក់វាផ្ទាល់ចូលទៅក្នុងស្រះចំនួន ១០ គីឡូក្រាម / ១០០ ម៉ែត្រការ៉េ ទឹកស្រះ ។

**ជីលាមកជ្រូក ៖** វាមានសារធាតុផូស្វ័រទាបជាងជីលាមកមាន់ដែរ ។ ការចិញ្ចឹមជ្រូកដាក់ទ្រុង នៅក្បែរស្រះចិញ្ចឹមត្រីហើយបង្ហូរកាកសំណល់លាមកជ្រូកចូលទៅក្នុងស្រះត្រី ជាវិធីមួយដ៏ល្អដែលត្រូវបានអ្នកចិញ្ចឹមត្រីជាច្រើនប្រទេសនៅលើពិភពលោកកំពុងអនុវត្ត។ ប៉ុន្តែគួជីករណ្ដៅនៅក្បែរទ្រុងជ្រូកភ្ជាប់ទៅនិងស្រះដើម្បីឱ្យលាមកជ្រូក និងទឹកដែលយើងលាងជ្រូកចូលទៅក្នុងអណ្ដៅសិន មុននិងបង្ហូរទឹកលាមកជ្រូកនោះចូលទៅក្នុងស្រះ។ បើពុំមានចិញ្ចឹមជ្រូកដាក់ទ្រុងទេ យើងត្រូវប្រមូលលាមកជ្រូកដាក់ចូលក្នុងអណ្ដៅជី រួចចាក់ទឹកត្រាំឱ្យបាន ១អាទិត្យ ទើបបង្ហូរចូលស្រះ។

**ជីលាមកគោ ក្របី ៖** វាមានសារធាតុអាសូត និងផូស្វ័រទាបជាងជីលាមកសត្វផ្សេងៗទៀត តែវាអាចរកបានច្រើននៅតាមជនបទ។ ក្នុងស្រះចិញ្ចឹមត្រី ១០០ ម៉ែត្រការ៉េ យើងអាចប្រើលាមកគោ ក្របីសើមចំនួន ១០០ គីឡូក្រាម ឬលាមកគោ ក្របីស្ងួត ៥០ គីឡូក្រាម ហើយមិនគួរយកវាទៅដាក់ផ្ទាល់ក្នុងស្រះទេ ត្រូវដាក់វាទៅក្នុងរណ្ដៅនៅក្បែរស្រះត្រី ដើម្បីបង្ហូរជាតិទឹកជីនោះចូលទៅក្នុងស្រះទើបវាល្អប្រសើរជាង ។

**ជីកំប៉ុស្ដ ៖** ជាជីដែលបានមកពីការរួមផ្សំរវាងកាកសំណល់រុក្ខជាតិ បន្លែ លាមកសត្វ ចំបើង និងដីដើម្បីបំបែកធាតុក្លាយជាជីដ៏ល្អសម្រាប់ដំណាំ ។វាអាចប្រើសម្រាប់ការចិញ្ចឹមត្រីបានដោយដាក់វាក្នុងរណ្ដៅជីលាមសត្វរួចទើបបង្ហូរចូលស្រះ។

**ជីបៃតង ៖** នៅពេលដែលយើងយកស្លឹករុក្ខជាតិ និងមែកមកប្រើជាជី យើងហៅថាជីបៃតង។ កសិករគួតែកត់សំគាល់ថា ប្រសិទ្ធភាពរបស់ជីបៃតង់កើតមាន នៅក្រោយពេលមែកធាង និងស្លឹករុក្ខជាតិរលួយ។ ប្រសិនបើយើងយកជីបៃតងទៅប្រើក្នុងស្រះត្រីបាន ២ ទៅ ៣ ថ្ងៃ វាចាប់ផ្តើមរលួយហើយស្រូបយកខ្យល់អុកស៊ីសែនដែលមានក្នុងស្រះត្រី រួចបញ្ចេញជាឧស្ម័នកាបូនិច (ខ្យល់ពុល) ដែលធ្វើឱ្យទឹកស្រះក្លាយទៅជាជាតិអាស៊ីត។ ដូច្នេះកសិករមិនគួរប្រើជីនេះផ្ទាល់ទៅក្នុងស្រះចិញ្ចឹមត្រីទេ។ ជីបៃតងត្រូវដាក់ឱ្យរលួយជាមួយនិងអណ្តៅជីលាមកសត្វសិន ទើបបង្ហូរទឹកជីចូលស្រះ ។



*ការរៀបចំរណ្តៅជីជាប់ស្រះចិញ្ចឹមត្រី*





*ការពិនិត្យសត្វល្អិតប្លង់តុងនៅក្នុងស្រះ*

## បរិមាណជី និងកំបោរដែលត្រូវប្រើ ក្នុងពេលរៀបចំស្រះត្រី

| បរិយាយ | ស្រះចាស់ (១០០ម$^{2}$) | ស្រះថ្មី (១០០ម$^{2}$) |
|---|---|---|
| កំបោរ | ៥ ទៅ ១០ គីឡូក្រាម | ១០ ទៅ ១៥ គីឡូក្រាម |
| លាមកគោ ឬ ក្របីសើម | ៦០ ទៅ ៨០ គីឡូក្រាម | ៨០ ទៅ ១០០គីឡូក្រាម |
| លាមកជ្រូកសើម | ២០ ទៅ ៣៥ គីឡូក្រាម | ២៥ ទៅ ៤០ គីឡូក្រាម |
| លាមកមាន់ ទាសើម | ១០ ទៅ ១៥ គីឡូក្រាម | ១៥ ទៅ ២០ គីឡូក្រាម |
| ស្លឹកទន្រ្ទានខែត្រ | ២០ ទៅ ៣០ គីឡូក្រាម | ៣០ ទៅ ៤០ គីឡូក្រាម |
| ដេ អា ប៉េ (ជីគីមី) | ០.៣ គីឡូក្រាម | ១ គីឡូក្រាម |
| អ៊ុយរ៉េ (ជីគីមី) | ០.៧ គីឡូក្រាម | ២ គីឡូក្រាម |

**បញ្ជាក់ :** ជីគីមីត្រូវលាយទឹកឱ្យរលាយគ្រាប់អស់សិន ទើបអាចបាចចូលទៅក្នុងស្រះ។ បើចៀសវាងបានគួរកុំប្រើជីគីមី ពីព្រោះនាំឱ្យខាតបង់ថវិការយើងត្រូវប្រើជីលាមកសត្វវិញ។

សរុបសេចក្ដីមក ដើម្បីឱ្យស្រះចិញ្ចឹមត្រីសម្បូចំណើធម្មជាតិ យើងមិនត្រូវប្រើជីទាំងអស់ខាងលើដាក់ចូលក្នុងស្រះផ្ទាល់ទេ ទោះបីជាជីនោះមានបរិមាណតិចតួចក៏ដោយ ព្រោះវានិងបង្កើតជាតិស្អុយបន្តិចម្ដងៗនៅបាតស្រះ។ ដូចនេះ ការដាក់ជីទៅក្នុងរណ្ដៅហើយបង្ហូរទឹកជីទៅក្នុងស្រះ ជាទង្វើដ៏ល្អប្រសើរសម្រាប់ស្រះចិញ្ចឹមត្រី។

**គ. ការរៀបចំស្រះ :**



*សកម្មភាពចាប់ត្រីកាច*

**ការរៀបចំស្រះត្រូវធ្វើតាមលំដាប់ដូចខាងក្រោម:**

- ត្រូវបូមពង្រីងស្រះ ដើម្បីចាប់ត្រីស្រែ កង្កែប អន្ទង់ ក្ដាម...
- ត្រូវស្ដាភក់បាតស្រះ ទុកជម្រៅមិនលើសពី ០.១៥ ម៉ែត្រ
- កែលំអស្រះឡើងវិញដូចជា លុបរន្ធក្ដាម និងជួសជុលភ្លឺស្រះ
- ត្រូវប្រើកំបោរក្រោយពេលបូមទឹកស្រះពង្រីង ឬ ប្រើកំបោរមុនពេលបញ្ចូលទឹក (ចំពោះស្រះថ្មី)
- តូវហាលស្រះឱ្យបានពី ១ ទៅ ២ ថ្ងៃ
- ត្រូវបញ្ចូលទឹកទៅក្នុងស្រះឱ្យបាន ១ ភាគ ៣ នៃជម្រៅស្រះ
- ត្រូវបង្ហូទឹកជីចេញពីរណ្ដៅជី ចូលក្នុងស្រះ
- ត្រូវបង្ហូទឹកបន្ថែមទៅក្នុងស្រះឱ្យពេញ ទុករយៈពេល ២ ទៅ ៣ ថ្ងៃ ឬ នៅពេលទឹកស្រះប្រែពណ៌បៃតងខ្ចី ទើបអាចលែងកូនត្រីចូលក្នុងស្រះបាន។

## ៣. ការដាក់កូនត្រីចិញ្ចឹម

### ក. ប្រភេទត្រីដាក់ចិញ្ចឹម

❒ គួរជ្រើសរើសប្រភេទត្រីទាំងឡាយណាដែលមានលក្ខណៈដូចខាងក្រោមនេះ :

❒ ងាយចិញ្ចឹមក្នុងស្រះ និងក្នុងស្រែះ

❒ ងាយរកពូជមកចិញ្ចឹម

❒ ធន់និងជំងឺ

❒ ស៊ីចំណីធម្មជាតិ និងចំណីបន្ថែមដែលអាចរកបាន

❒ មានតម្លៃក្នុងទីផ្សារ ឬ ប្រជាជននិយមចូលចិត្តបរិភោគ

❒ ចំពោះប្រភេទត្រីទាំងនេះ មានដូចជា ត្រីឆ្ពិន កន្ធរ ក្រាញ់ ប្រា ព្រលូង ទីឡាព្យ៉ា កាបស កាបក្បាលធំ កាបសាមញ្ញ កាបអណ្ដែត.........។

### ១. ត្រីឆ្ពិន


ត្រីឆ្ពិន

ជាប្រភេទត្រីក្នុងស្រុក រស់នៅតាមទន្លេស្ទឹង បឹងបួរ

❒ ពេលនៅតូច វាស៊ីចំណីច្រើនប្រភេទដូចជា ពពួកសត្វប្លង់តុង ក្រុមស្លឹករុក្ខជាតិជាសារាយតូចៗ និងសត្វល្អិតតូចៗ ផ្សេងទៀតដូចជាកណ្ដៀរ...

❒ ពេលធំវាស៊ីចំណី ដូចជា កាកសំណល់បន្លែ ស្លឹករុក្ខជាតិ ចក ត្រកួនជាដើម

- អាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយជាដើម
- ចូលចិត្តរស់នៅស្រទាប់លើ និងកណ្តាល
- អាចរស់នៅក្នុងមជ្ឈដ្ឋានទឹកនឹង ទឹកហូរ ដូចជា ទន្លេ ស្ទឹង បឹង ក្នុងស្រះចិញ្ចឹមត្រីជាដើម ដែលមានប៉េហាស់សមស្របពី ៦.៥ ទៅ ៧.៥
- អាចមានទម្ងន់ពី ០.២ ទៅ ០.៥ គីឡូក្រាម រយៈពេលចិញ្ចឹមក្នុងស្រះ ១ ឆ្នាំ បើមានការគ្រប់ល្អ
- ត្រីឆ្អិនអាចបន្តពូជបាននៅអាយុ ៨ ខែ ឡើងទៅ
- ធន់នឹងជំងឺ ។

## ២. ត្រីកន្ធរ

ជាប្រភេទត្រីក្នុងស្រុក មានតម្លៃសេដ្ឋកិច្ចខ្ពស់ រស់នៅក្នុងទឹកដូចជា បឹង ត្រពាំង ថ្លុក ស្រែ និងប្រឡាយ ។

- ចូលចិត្តស៊ីចំណីច្រើនប្រភេទ ដូចជា បន្លែ ស្លឹករុក្ខជាតិ ចក ត្រកួន កណ្តៀវ....តែចំណីសំខាន់ គឺប្លុងតុង
- ចូលចិត្តរស់នៅស្រទាប់លើ និងកណ្តាល
- អាចស៊ីចំណីបន្ថែម ដូចជាកន្ទក់ ចុងអង្ករ ពោធ សណ្តែក កាកសំណល់ផ្ទះបាយជាដើម
- អាចរស់នៅមជ្ឈដ្ឋានទឹក ដែលមានជាតិជូរតិចដែលមានប៉េហាស់សមស្របពី ៥.៦ ទៅ ៦



*ត្រីកន្ធរ*

- ❐ អាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានកម្រិតអុកស៊ីសែនទាប
- ❐ ត្រីមានទម្ងន់ ៥០ ទៅ ១០០ ក្រាម (០.៥ ទៅ ១ ខាំ) រយៈពេល ១ ឆ្នាំ ក្នុងស្រះចិញ្ចឹម
- ❐ ត្រីអាចបន្តពូជបាននៅ ក្នុងស្រះ ពេលវាមានអាយុលើពី ៧ ខែ
- ❐ ធន់និងជំងឺ ។

## ៣. ត្រីកាប ស

ជាប្រភេទត្រីក្រៅស្រុក មានប្រភពពីប្រទេសចិន រស់នៅក្នុងតំបន់ទឹកសាប ។ ជាត្រីដែលងាយស្រួលចិញ្ចឹម រស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមានគុណភាពល្អ ។

- ❐ ស៊ីសត្វល្អិត ប្លង់តុងសត្វ ពេលត្រីនៅតូច និងស៊ីប្លង់តុងរុក្ខជាតិ នៅពេលវាធំ
- ❐ អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សំណែក កាកសំណល់ផ្ទះបាយជាដើម
- ❐ អាចរស់នៅក្នុងស្រទាប់លើ និងកណ្តាល
- ❐ អាចរស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមានប៉េហាស់ សមស្រប ពី ៦.៥ ទៅ ៨ និងសីតុណ្ហភាព២០-៣០ អង្សាសេ



ត្រីកាប ស

- ❐ ពេញវ័យនៅពេលវាមានអាយុពី ១ ទៅ ២ ឆ្នាំ
- ❐ លូតលាស់ល្អ អាចមានទម្ងន់ពី ០.៥ ទៅ ០.៧ គីឡូក្រាម ក្នុងរយៈពេល ១ ឆ្នាំ
- ❐ មិនអាចបន្តពូជក្នុងស្រះបានទេ ។

## ៨. ត្រីទីឡាព្យ៉ា (ទីឡាព្យ៉ាឆ្នូតបញ្ឈរ)

ជាប្រភេទត្រីក្រៅស្រុក មានប្រភពពីប្រទេសអាហ្វ្រិកខាងជើង។ រស់នៅក្នុងតំបន់ទឹកសាប និងអាចរស់នៅក្នុងទឹកភ្លាវ ។ជាត្រីងាយស្រួលចិញ្ចឹម ព្រោះវាអាចធន់និងមជ្ឈដ្ឋានរស់នៅ ដែលមានកម្រិតបរិមាណខ្យល់អុកស៊ីសែនរលាយក្នុងទឹកទាប ។

- ❒ ស៊ីចំណីចម្រុះ ( រុក្ខជាតិក្នុងទឹក ស្លែ ជន្លេន កណ្តៀរ ) អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោតសណ្តែក កាកសំណល់ផ្ទះបាយ ជាដើម
- ❒ រស់នៅគ្រប់ស្រទាប់ទឹក
- ❒ អាចរស់នៅមជ្ឈដ្ឋានទឹកដែលមានជាតិជូរតិចដែលមាន ប៉េហាស់ល្អពី ៤ ទៅ ៩ សីតុណ្ហភាព ១៤-៤០ អង្សាសេ
- ❒ លូតលាស់ល្អអាចមានទម្ងន់ពី ០.២ ទៅ ០.៥ គីឡូក្រាម ( ២ ខាំ ទៅ ៥ ខាំ) ក្នុងរយៈពេលចិញ្ចឹម ៨ ខែ
- ❒ ពេញវ័យនៅពេលវាមានអាយុ ៤ ខែ ឡើងទៅ
- ❒ ងាយពង និងញាស់កូនក្នុងស្រះ ដោយធម្មជាតិ
- ❒ ធន់នឹងជំងឺ ។



*ត្រីទីឡាព្យ៉ា*

## ៥. ត្រីកាបសាមញ្ញ

ជាប្រភេទត្រីក្រៅស្រុក  រស់នៅក្នុងតំបន់ទឹកសាប  ជាប្រភេទត្រីដែលងាយស្រួលចិញ្ចឹម  ព្រោះវាអាចធន់និងមជ្ឈដ្ឋានរស់នៅដែលមានកម្រិតបរិមាណអុកស៊ីសែនរលាយក្នុងទឹកទាប ។

- ❒ ស៊ីចំណីចម្រុះ (កូនខ្យង ខ្មៅ ក្តាម ជន្លេន កណ្តៀរ សត្វល្អិត រុក្ខជាតិក្នុងទឹក...
- ❒ អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយ ជាដើម
- ❒ អាចរស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមានប៉េហាស់ពី ៥.៥ ទៅ ៨.៥ និងសីតុណ្ហភាព ២០ ទៅ ៣០ អង្សាសេ
- ❒ រស់នៅស្រទាបបាត
- ❒ លូតលាស់បានល្អអាចពី ០.៥ ទៅ ១ គីឡូក្រាម ក្នុងរយៈពេល ១ ឆ្នាំ
- ❒ ពេញវ័យនៅពេលវាមានអាយុ ៨ ខែ ឡើងទៅ
- ❒ អាចបន្តពូជបាននៅក្នុងស្រះ
- ❒ ធន់នឹងជំងឺ ។



*ត្រីកាបសាមញ្ញ*

## ៦. ត្រីកាបឥណ្ឌា (ម្រិហ្គាល់)

ជាប្រភេទត្រីក្រៅស្រុក រស់នៅក្នុងតំបន់ទឹកសាប ជាប្រភេទត្រីដែលងាយស្រួលចិញ្ចឹម ។

- ❒ ស៊ីចំណីចម្រុះ (សត្វល្អិតក្នុងទឹក រុក្ខជាតិក្នុងទឹក ចក បាយទា...)
- ❒ អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយ ជាដើម

❒ រស់នៅស្រទាប់បាត

❒ អាចរស់នៅមជ្ឈដ្ឋានទឹក ដែលមានប៉េហាស់ពី ៥.៥ ទៅ ៨.៥ និងសីតុណ្ហភាព ២០-៣០ អង្សាសេ

❒ លូតលាស់ល្អអាចពី ០.៥ ទៅ ០.៧ គីឡូក្រាមក្នុងរយៈពេល ១ ឆ្នាំ

❒ ពេញវ័យនៅពេលវាមានអាយុ ១.៥ ឆ្នាំ ឡើងទៅ

❒ ធន់នឹងជំងឺ ។



ត្រីម្រីហ្គាល់

## ខ. ចំនួន និងទំហំកូនត្រីដាក់ចិញ្ចឹម

❒ គួរដាក់កូនត្រីចិញ្ចឹមពី ៣ ទៅ ៤ ក្បាល ក្នុង ១ ម៉ែត្រការ៉េ ឬ ពី ៣០០ ទៅ ៤០០ ក្បាល ក្នុង ១០០ ម៉ែត្រ ការ៉េនៃផ្ទៃស្រះ ។

❒ គួដាក់កូនត្រីចិញ្ចឹមចម្រុះចាប់ពី ៣ ប្រភេទឡើងទៅ ដើម្បីប្រើប្រាស់ចំណីអស់ពីក្នុងស្រះ



❒ ប្រភេទត្រីត្រូវដាក់ចិញ្ចឹមតាមភាគរយ មានដូចខាងក្រោមនេះ :

| ប្រភេទត្រី | ឆ្អិន | ទីឡាព្យ៉ា | កាបស | កាបសាមញ្ញ/ឥណ្ឌា |
|---|---|---|---|---|
| ប្រភេទត្រីឆ្អិន ជាសំខាន់ | ៤០ ភាគរយ | ៣០ ភាគរយ | ២០ ភាគរយ | ១០ ភាគរយ |
| ប្រភេទត្រីទីឡាព្យ៉ា ជាសំខាន់ | ៣០ ភាគរយ | ៤០ ភាគរយ | ២០ ភាគរយ | ១០ ភាគរយ |
| ក្នុងករណីចិញ្ចឹមតែ ៣ប្រភេទ | | ៥០ ភាគរយ | ៤០ ភាគរយ | ១០ ភាគរយ |

ដើម្បីទទួលបានផលពីការចិញ្ចឹមត្រី កូនត្រីដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ និងមានទំហំធំប្រវែងពី ៥ ទៅ ៦ សង់ទីម៉ែត្រ ឬ ៣ ថ្នាំងដៃ ដើម្បីឱ្យកូនត្រីគេចផុតពីសត្រូវ ដែលធ្វើឱ្យកូនត្រីមានអត្រារស់ច្រើន។ម្យ៉ាងទៀតការដាក់កូនត្រីចិញ្ចឹមមានទំហំធំធ្វើឱ្យការលូតលាស់កូនត្រីបានធាត់ធំឆាប់រហ័ស ។



## គ. ពេលវេលាដាក់កូនត្រីចិញ្ចឹម

ជាទូទៅ យើងអាចចិញ្ចឹមត្រីបានគ្រប់ពេលវេលា អាស្រ័យទៅនឹងស្រះមានទឹកគ្រប់គ្រាន់ ។ ប៉ុន្តែចំពោះស្រះដែលពឹងផ្អែកទៅលើប្រភពទឹកភ្លៀង ត្រូវដាក់នៅពេលស្រះមានទឹកគ្រប់គ្រាន់ ដើម្បីឱ្យកូនត្រីចិញ្ចឹមបានរយៈពេលយូរ និងមានការលូតលាស់ធំធាត់បានល្អ ។

## ឃ. ការដឹកជញ្ជូនកូនត្រី

ការដឹកជញ្ជូនកូនត្រីមាន ២ របៀប គឺ ការដឹកជញ្ជូនដោយបិទជិត និងការដឹកជញ្ជូនដោយចំហរ ។

❒ **ការដឹកជញ្ជូនដោយបិទជិត :** គឺជាការដឹកជញ្ជូនកូនត្រីដោយប្រើថង់ប្លាស្ទិក និង ខ្យល់អុកស៊ីសែនសម្រាប់ដឹកជញ្ជូនផ្លូវឆ្ងាយ ឬ ដឹកជញ្ជូនផ្លូវជិតក៏បាន។ ការដឹកជញ្ជូននេះត្រូវមានសម្ភារៈ ដូចជា ថង់ប្លាស្ទិក កៅស៊ូចង ថង់ កញ្ជោ សម្រាប់ដាក់ថង់កូនត្រី ខ្សែចង និងខ្យល់អុកស៊ីសែន។

**ឧទាហរណ៏:** ថង់ប្លាស្ទិក ដែលមានទំហំ ៦០ សង់ទីម៉ែត្រ X ១០០ សង់ទីម៉ែត្រ អាចដាក់កូនត្រីចំនួនពី ៣០០ ទៅ ៥០០ ក្បាល បើកូនត្រីមានទំហំ ៣ ទៅ ៥ សង់ទីម៉ែត្រ ។ ដើម្បីដឹកជញ្ជូនកូនត្រីឱ្យបានល្អ ចៀសវាងការធ្លាយថង់ក្នុងការដឹកជញ្ជូនគួរប្រើថង់ត្រួតគ្នា ២ ជាន់ និងត្រូវចងគួទថង់ថែមទៀត ។



*ការដឹកជញ្ជូនកូនត្រីផ្លូវឆ្ងាយ ត្រូវប្រើថង់ប្លាស្ទិក និងត្រូវបំពេញដោយខ្យល់អុកស៊ីសែន*

❒ **ការដឹកជញ្ជូនដោយចំហរ :** គឺការដឹកជញ្ជូនកូនត្រីប្រើសម្រាប់ផ្លូវជិតអាចប្រើសម្ភារៈ ដូចជាធុង ប៉ោតជាដើម ។ល ។



*របៀបដឹកជញ្ជូនកូនត្រីក្នុងចម្ងាយផ្លូវជិតៈ ដោយប្រើធុង ឆ្នាំង ឬ សម្ភារៈស្អាតល្អផ្សេងៗទៀត*

យើងត្រូវជ្រើសរើសយករបៀបដឹកជញ្ជូនណាមួយ ដោយយោងទៅតាមសភាពជាក់ស្តែង នៃចំងាយផ្លូវក្នុងពេលដឹកជញ្ជូន។  ការដឹកជញ្ជូនកូនត្រីគួរធ្វើនៅពេលព្រឹក  ពេលអាកាសធាតុត្រជាក់ ។ ចំនួនកូនត្រីដែលត្រូវដឹកជញ្ជូន គឺអាស្រ័ទៅលើកូនត្រីចម្ងាយផ្លូវ និងរយៈពេលដឹកជញ្ជូន ។

### ង. របៀបលែងកូនត្រី

❒ ពេលវេលាសមស្របសម្រាប់លែងកូនត្រីត្រូវធ្វើនៅពេលព្រឹក ជាពិសេសចាប់ពីម៉ោង ៨ ទៅ ១១ ព្រឹក

❒ ករណីទឹកស្រះក្តៅខ្លាំង យើងត្រូវយកដៃកូរទឹក ពីក្រោមមកលើដើម្បីឱ្យទឹកស្រះមានកម្តៅប្រហាក់ប្រហែលគ្នា

❒ មុនពេលលែងកូនត្រីត្រាំថង់កូនត្រីក្នុងទឹកស្រះរយៈ ១០-១៥ នាទី ដើម្បីសីតុណ្ហភាពទឹកក្នុងថង់កូនត្រីមានកម្តៅប្រហាក់ប្រហែលគ្នា និងកម្តៅទឹកស្រះ

❒ ស្រាយមាត់ថង់រួចយកដៃបាចទឹកស្រះបញ្ចូលថង់បន្ទាប់មកផ្អៀកថង់ ដើម្បីឱ្យកូនត្រីហែលចេញតាមសម្រួល។



*ទុកឱ្យវាអណ្តែតក្នុង ១០ នាទី*



*បាចទឹកស្រះបញ្ចូលថង់កូនត្រី*



*ផ្អៀងមាត់ថង់ឱ្យកូនត្រីហែលចេញតាមសម្រួល*

## ៤. ការដាក់ជីបន្ថែមក្រោយពេលដាក់ត្រីចិញ្ចឹម

ក្រោយពីដាក់កូនត្រីចិញ្ចឹមរយៈពេលពី ១០ ទៅ ១៥ ថ្ងៃ យើងត្រូវពិនិត្យមើលទឹកស្រះ ឬ មើលចំណីធម្មជាតិក្នុងស្រះ បើឃើញទឹកស្រះមានពណ៌បៃតងចាស់ មានន័យថាក្នុងស្រះមានចំណីធម្មជាតិប្លង់តុង តែបើទឹកស្រះលែងមានពណ៌បៃតង ត្រូវបន្ថែមជីតាមវិធីសាស្ត្រដូចខាងក្រោម ៖

### ក. ជីធម្មជាតិ

❐ ជីករណ្ដៅនៅក្បែរស្រះទំហំ ១ ទៅ ១.៥ ម៉ែត្របួនជ្រុង ឬ ជីកមានរាងជាបួនជ្រុងទ្រវែងក៏បានជម្រៅ ៥០ សង់ទីម៉ែត្រ និងមានចង្អូរ ឬ បំពង់សម្រាប់បង្ហូរទឹកជីចូលស្រះ។ ទឹកជីក្នុងរណ្ដៅត្រូវបង្ហូរចូលស្រះនៅពេលថ្ងៃ

❐ ក្នុងរណ្ដៅត្រូវដាក់ជីកំប៉ុស្ដ ឬ ជីលាមកសត្វគោ ក្របី ជ្រូក មាន់ ទា និងជីរុក្ខជាតិបៃតងមានដូចជា ដើមទន្រ្ទានខែត្រ កាកសំណល់បន្លែងាយរលួយ និងត្រូវចាក់ទឹកក្នុងរណ្ដៅត្រាំជីរៀងរាល់ថ្ងៃ ដើម្បីឱ្យជីឆាប់រលួយរួចបង្ហូរទឹកជីចូលស្រះ

❐ កាកសំណល់ជីក្នុងរណ្ដៅត្រូវប្ដូរសារជាថ្មីក្នុងរយៈពេលពី ២០ ទៅ ៣០ ថ្ងៃ

❐ ក្នុងករណីទឹកស្រះមានពណ៌បៃតងចាស់ ឬ ពណ៌ត្នោត ឬ ទឹកមានធំក្លិនស្អុយ ត្រូវបញ្ឈប់ការបង្ហូរទឹកជីចូលស្រះមួយរយៈ។







## ខ. ជីគីមី

ជីគីមីក៏មានសារៈសំខាន់សម្រាប់បង្កើតប្លង់តុង។ បរិមាណជីគីមីសម្រាប់ប្រើដាក់ស្រះចិញ្ចឹមត្រីគឺ ជីដេអាប៉េ ចំនួន0.៣គីឡូក្រាម និងជីអ៊ុយរ៉េ 0.៧ គីឡូក្រាម កូរលាយជាមួយទឹកឱ្យរលាយគ្រាប់អស់សិន ទើបយកទៅបាចឱ្យសព្វលើផ្ទៃទឹកស្រះ ទំហំ ១០០ ម៉ែត្រការ៉េ។ ក្នុងកំឡុងពេលពី ២ ទៅ ៥ថ្ងៃក្រោយមក ទឹកស្រះនិងប្រែពណ៌បៃតង។ ត្រូវឧស្សាហ៍បន្ថែមជីតាមបរិមាណខាងលើរៀងរាល់សប្តាហ៍ ដើម្បីរក្សាទឹកស្រះឱ្យមានពណ៌បៃតងជានិច្ច។ ក្នុងករណីទឹកស្រះមានពណ៌បៃតងចាស់ត្រូវបញ្ឈប់ការដាក់បង្ហូរទឹកជីមួយរយៈសិន។

## ៥. ការផ្តល់ចំណី

### ក. ប្រភេទចំណី

ចំណីមានសារៈសំខាន់ណាស់សម្រាប់ការលូតលាស់របស់ត្រី ។ ចំណីមាន ២ ប្រភេទ គឺចំណីធម្មជាតិ និងចំណីបន្ថែម ។

**ចំណីធម្មជាតិ:** រួមមានបួលង់តុងសត្វ បួលង់តុងរុក្ខជាតិ និង សត្វស្រទាប់បាតដូចជា ខ្ចៅ ខ្យង ជន្លេនក្រហមជាដើម ។

**ចំណីបន្ថែម:** បានមកពីការផ្សំប្រភេទចំណីមួយចំនួនដូចជា: កន្ទក់ ម្សៅត្រី ចុងអង្ករ ពោត សណ្តែក ឬ ចំណីគ្រាប់ជាដើម ។ ក្រៅពីនេះ ចំណីដែលអាចរកបាននៅក្នុងភូមិមាន ចកបាយទា ពងទឹក កណ្តៀរ ជន្លេន កាកសំណល់ផ្ទះបាយ បន្លែ និងកាកសំណល់ទីសត្តឃាដ ។ល ។ ក៏ជាចំណីបន្ថែមសម្រាប់ត្រីផងដែរ ។

### ខ. ការផ្តល់ចំណី

ការលូតលាស់របស់ត្រី គឺអាស្រ័យដោយលើគុណភាព និងបរិមាណចំណីដែលផ្តល់ឱ្យត្រី ។

- ការផ្តល់ចំណីត្រីត្រូវកំណត់ទីកន្លែងដាក់ចំណីជាក់លាក់ និងទៀងទាត់ពេលវេលា
- ចំណីត្រូវផ្តល់នៅពេលព្រឹកចន្លោះពីម៉ោង ៩ ទៅ ១០ និងពេលរសៀលចន្លោះពីម៉ោង ៤ ទៅ ៥
- បរិមាណចំណីដែលផ្តល់ឱ្យត្រីត្រូវប្រែប្រួលទៅតាមទំហំរបស់ត្រី គឺពី ៣ ទៅ ៥ ភាគរយនៃទម្ងន់ត្រី សរុបក្នុងស្រះ

❒ ចំពោះចំណីដែលអណ្តែតដូចជា ចកបាយទា ពងទឹក កាកសំណល់បន្លែ....ត្រូវធ្វើស៊ុមដាក់នៅកាច់ជ្រុងស្រះ

❒ ចំណីដែលផ្សំឡើងពី កន្ទក់ ម្សៅត្រី ចុងអង្ករ ពោត សណ្តែក... មុននិងដាក់ឱ្យត្រីស៊ីត្រូវចម្អិនឱ្យឆ្អិនទុកឱ្យត្រជាក់រួចពូតជាដុំដាក់ក្នុងកញ្ច្រែង ហើយពន្លិចក្នុងទឹកជម្រៅពី ០.៣ ទៅ ០.៥ ម៉ែត្រ

❒ នៅពេលផ្តល់ចំណី ត្រូវត្រួតពិនិត្យមើលត្រីស៊ីចំណីជាក់ស្តែងនៅក្នុងកញ្ច្រែង ក្រោយពីដាក់រយៈពេល ១ ម៉ោង ចៀសវាងផ្តល់ចំណីច្រើនពេក ត្រីស៊ីមិនអស់នាំឱ្យខូចគុណភាពទឹក ។





*ការដាក់ចំណីឱ្យត្រីដោយប្រើកញ្ច្រែង*




ជាទូទៅកសិករភាគច្រើន តែងតែផ្តល់កន្ទក់ឱ្យត្រីស៊ី ។ តាមបទពិសោធន៍ដែលបានស្រាវជ្រាវ បានបង្ហាញឱ្យឃើញថា ការផ្តល់ចំណីកន្ទក់ម៉ត់អស់ ៥ គីឡូក្រាម ទទួលផលត្រីបាន ១ គីឡូក្រាម ។ ដូចច្នេះគួរចៀសវាងការផ្តល់ចំណីកន្ទក់សុទ្ធដោយការបាចទៅលើផ្ទៃស្រះ នាំឱ្យខាតបង់គួរយកកន្ទក់ចម្អិនជាម្សៅត្រី និងចុងអង្ករឱ្យឆ្អិនរួចទុកឱ្យត្រជាក់ទើបដាក់ឱ្យត្រីស៊ីជាការប្រសើរ ។

# ៦. ការគ្រប់គ្រងស្រះចិញ្ចឹមត្រី

ដើម្បីឱ្យការចិញ្ចឹមត្រីទទួលបានជោគជ័យ យើងត្រូវយកចិត្តទុកដាក់លើកត្តាមួយចំនួនបន្ថែមទៀតដូចជា :

- ត្រួតពិនិត្យភ្លឺស្រះក្រែងមានធ្លុះធ្លាយ បាក់ស្រុត....ដើម្បីចៀសវាងការលេចទឹក
- ពិនិត្យគុណភាពទឹកស្រះ ធ្វើឱ្យមានពណ៌បៃតងជានិច្ច

*រូបភាពសត្វល្អិតបង្កំតុងក្នុងស្រះ*

*ការត្រួតពិនិត្យសត្វបង្កំតុងក្នុងស្រះ*



- សំអាតស្មៅ ដែលដុះតាមខាងៗស្រះ
- សំអាតរុក្ខជាតិទឹកដែលមិនចាំបាច់ចេញពីស្រះត្រី

*ការស្រង់យកដើមកំប្លោកចេញពីស្រះ*



❒ ពិនិត្យ និងកំចាត់សត្វដែលបំផ្លាញត្រីក្នុងស្រះមានដូចជា ពស់ កង្កែប សត្វក្រចាត...

❒ បើឃើញត្រីមានជំងឺ ឬ សត្វងាប់ ត្រូវស្រង់យកចេញជាបន្ទាន់

❒ នៅពេលព្រឹកប្រលឹមប្រសិនបើឃើញត្រីងើបច្រើនមានសកម្មភាពហែលខុសពីធម្មតា ( មិនផ្អើល) នោះ បញ្ជាក់ថា ត្រីខ្វះខ្យល់ដកដង្ហើម ឬ ត្រីពុល ។ ជួបប្រទេះករណីដូចនេះ ត្រូវធ្វើទឹកស្រះឱ្យមានចលនា ឬ បូមទឹកថ្មីមានគុណភាពល្អបន្ថែមបញ្ចូលទៅក្នុងស្រះ និងត្រូវផ្អាកការផ្តល់ចំណី និងជីមួយរយៈពេលសិន ។



ត្រីពុលខ្វះខ្យល់អុកស៊ីសែន



បាចទឹកក្នុងស្រះត្រីពេលឃើញត្រីពុល

**កត្តាដែលត្រូវចៀសវាង**

- មិនត្រូវអោយគោ ក្របី ជ្រូក ឬ សកម្មភាពផ្សេងៗដែលធ្វើឱ្យល្អក់ទឹកស្រះ
- មិនត្រូវឱ្យកាកសំណល់ផ្សេងៗដូចជា ត្រឡោកដូង សំបកផ្លែឈើ និងរុក្ខជាតិចូលក្នុងស្រះ
- មិនត្រូវប្រើសារជាតិពុលផ្សេងៗ ដូចជា ថ្នាំសម្លាប់សត្វល្អិតចង្រៃ ឬ ម្សៅសាប៊ូ នៅក្នុង និងជុំវិញស្រះ

❐ មិនត្រូវត្រាំស្លឹកត្នោត ឈើ ឬស្សី ឬ រុក្ខជាតិផ្សេងៗ ដែលធ្វើឱ្យទឹកស្រះចិញ្ចឹមត្រីមានជាតិពុល



*ហាមបោកគក់ខោអាវក្នុងស្រះ ចិញ្ចឹមត្រី*



*ហាមត្រាំស្លឹកត្នោត ឬ ស្លឹកឈើ ក្នុងស្រះចិញ្ចឹមត្រី*



*ហាមលាងសម្ភារៈថ្នាំពុល ក្នុងស្រះចិញ្ចឹមត្រី*

## ៧. ការប្រមូលផល

### ក. ការប្រមូលផលរំលស់

ក្រោយពីចិញ្ចឹមបានរយៈពេល ៣ ខែ ឡើងទៅ អាចចាប់ផ្តើមចាប់ត្រីដែលមានទំហំធំហួបជាបណ្តើរៗ ។

❐ ការចាប់ត្រីរំលស់នេះអាចធ្វើឱ្យត្រីដែលនៅសល់ក្នុងស្រះមានការលូតលាស់លឿន

❒ ការចាប់ត្រីហូបប្រចាំថ្ងៃ អាចប្រើឧបករណ៍ដូចជា សន្ទូច សំណាញ់ ឬ អួន

❒ ចំពោះត្រីទីឡាព្យ៉ា បើអ្នកប្រមូលផលរំលស់ដោយចាប់ត្រីមេធំៗ ហូបមុននោះមិនល្អទេ បើសិនជាអ្នកចង់ទុកវាធ្វើត្រីមេពូជ ត្រូវទុកត្រីមេដំបូង ព្រោះកូនត្រីរបស់វាធំមិនទាន់បានស្រួលបួលផង វាក៏ចាប់ផ្តើមផ្តើតកូនតទៀតហើយ ដែលធ្វើឱ្យត្រីកាន់តែតូចទៅៗ ។



*ការស្ទូចត្រីចាប់ហូបប្រចាំថ្ងៃ*



*ការបង់សំណាញ់ចាប់ត្រីហូបប្រចាំថ្ងៃ*

## ខ. ការប្រមូលផលទាំងស្រុង

- ❒ ត្រូវធ្វើឡើងនៅពេលត្រីមានតម្លៃថ្លៃ នៅពេលមានតម្រូវការចាំបាច់ ឬ នៅពេលស្រះជិតរីងអស់
- ❒ ការប្រមូលផលទាំងស្រុង ធ្វើឡើងដោយប្រើម៉ាស៊ីនបូមទឹក ដើម្បីពង្រីងស្រះចាប់ត្រី
- ❒ មុនពេលបាច ឬ បូមពង្រីងស្រះ ចាំបាច់ត្រូវត្រៀមឧបករណ៍ សម្ភារៈសម្រាប់ប្រស់ត្រីជាមុនសិន
- ❒ ក្រោយពេលប្រមូលផលត្រីហើយអ្នកគួតែស្តារភក់បាតស្រះ និងជួសជុលស្រះ ឱ្យបានល្អទាន់ពេលដីនៅសើម

សម្រាប់ការដាក់ចិញ្ចឹមត្រីទៀតជាបន្តទៀត ។



*សកម្មភាពប្រមូលផលត្រីទាំងស្រុង ដើម្បីលក់ និងសម្រាប់ទុកហូប*

## ៨. ការកត់ត្រាចំណាយ និងចំណូល

ការកត់ត្រាគួរតែកត់ឱ្យបានម៉ត់ចត់តែស្រសើរ ព្រោះវាមានសារៈសំខាន់ណាស់ អាចឱ្យយើងដឹងពីការចំណាយ និងចំណូលថវិការ ក្នុងរយៈពេលចិញ្ចឹមត្រី។

### តារាងចំណាយ

| ល.រ | ថ្ងៃ ខែ ឆ្នាំ | ប្រភេទមុខចំណាយ | ចំនួន | តម្លៃ/ឯកតា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | បូមទឹកចេញ និងចូលស្រះ | | | | |
| | | ទិញកំបោរ | | | | |
| | | ជីគីមី | | | | |
| | | កូនត្រីពូជ | | | | |
| | | ចំណី | | | | |
| | | ឈ្នួលដឹកជញ្ជូនកូនត្រី | | | | |

## តារាងចំណូល

| ល.រ | ថ្ងៃ ខែ ឆ្នាំ | ប្រភេទមុខចំណូល | ចំនួន | តម្លៃ/ឯកត្តា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | លក់កូនត្រីទីឡាព្យ៉ា | | | | |
| | | ត្រីចាប់ហូប | | | | |
| | | ត្រីឱ្យគេ | | | | |
| | | លក់ត្រីសាច់ | | | | |
| | | ត្រីទុកពូជ | | | | |

## ៩. កត្តាសំខាន់ៗដែលធ្វើឱ្យការចិញ្ចឹមត្រីទទួលបានជោគជ័យ

- ❒ ត្រូវជ្រើសរើសទីតាំង និងជីកស្រះឱ្យបានសមស្រប និងមានពន្លឺថ្ងៃគ្រប់គ្រាន់
- ❒ ស្រះត្រូវមានភ្លឺព័ទ្ធជុំវិញ ខ្ពស់ មាំ និងដាំស្មៅ ដើម្បីកាត់បន្ថយការហូរច្រោះ
- ❒ ត្រូវរៀបចំស្រះឱ្យបានត្រឹមត្រូវតាមបច្ចេកទេស មុនពេលដាក់ត្រីចិញ្ចឹម
- ❒ ពេលបង្ហូរទឹកចូលស្រះ ត្រូវចងស្បៃ នឹងមាត់បំពង់ ដើម្បីការពារត្រីកាច និងសត្វផ្សេងៗស៊ីកូនត្រី
- ❒ ត្រូវដាក់កូនត្រីចិញ្ចឹមនៅពេលស្រះមានទឹកគ្រប់គ្រាន់ (ដើមរដូវភ្លៀង)

- កូនត្រីដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ ប្រវែងពី ៥ ទៅ ៦ សង់ទីម៉ែត្រ ឬ ៣ ថ្នាំងដៃស
- ចំនួនកូនត្រីចិញ្ចឹមត្រូវដាក់ពី ៣ ទៅ ៤ ក្បាល ក្នុង ១ ម៉ែត្រការ៉េ
- ដាក់ចិញ្ចឹមត្រីច្រើនប្រភេទ ដើម្បីប្រើអស់លទ្ធភាពចំណីដែលមាននៅក្នុងស្រះ
- ការដាក់ជីជាប្រចាំថ្ងៃ ដើម្បីឱ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ដើម្បីឱ្យកូនត្រីធំធាត់ល្អ
- គួរផ្តល់ចំណីបន្ថែមដែលមានគុណភាពល្អ និងទៀងទាត់ពេលវេលា
- ត្រូវសំអាតរុក្ខជាតិទឹក ( ព្រលិត ឈូក កំប្លោក ចកធំ...) ឱ្យអស់ពីក្នុងស្រះ ។





# ផ្នែកទី ២ : បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ

## ផលប្រយោជន៍នៃការចិញ្ចឹមត្រីក្នុងស្រែ

អត្ថប្រយោជន៏ជាច្រើនដែលទទួលបានពីការចិញ្ចឹមត្រីក្នុងស្រែ រួមមានដូចខាងក្រោម:

- ❒ កាត់បន្ថយការចំណាយថវិការសម្រាប់ការទិញថ្នាំគីមីសម្លាប់សត្វល្អិត ដោយសារត្រីស៊ីសត្វល្អិតទាំងនោះ
- ❒ មិនចំណាយកម្លាំងពលកម្មសំអាតស្មៅក្នុងស្រែ ដោយសារត្រីស៊ីស្មៅ ឬ រុក្ខជាតិដែលមានផលប៉ះពាល់ដល់ដំណាំស្រូវ
- ❒ លាមកត្រីជាជីធម្មជាតិដ៏ល្អសម្រាប់ការលូតលាស់ដំណាំស្រូវ
- ❒ ការដាក់ជីដល់ដំណាំស្រូវ បានធ្វើឱ្យសម្បូរចំណីធម្មជាតិដល់ត្រីទៀតផង
- ❒ ផ្កា និងគ្រាប់ស្រូវដែលជ្រុះទៅក្នុងស្រែ ជាចំណីរបស់ត្រី
- ❒ ជួយកាត់បន្ថយការចំណាយថវិការសម្រាប់ទិញចំណីបន្ថែមឱ្យត្រី
- ❒ ធ្វើឱ្យដីស្រែមិនហាប់ ស្រូវបែកគុម្ពល្អ ដោយសារការរកចំណីរបស់ត្រី

- ទិន្នផលស្រូវកើនឡើងជាងមុន (ប្រមាណពី ១០ ទៅ ១៥ ភាគរយ ធៀបជាមួយផលស្រូវដែលមិនបានដាក់ត្រីចិញ្ចឹម)
- ការចិញ្ចឹមត្រីក្នុងស្រែ យើងទទួលបានផលស្រូវ និងផលត្រី
- កាត់បន្ថយការចំណាយថវិការទិញត្រីពីផ្សារហូប មិនតែប៉ុណ្ណោះបានផលត្រីលក់ និងបង្កើនប្រាក់ចំណូលក្នុងក្នុងគ្រួសារ
- អ្នកដែលគ្មានដីជីកស្រះចិញ្ចឹមត្រី ក៏អាចចិញ្ចឹមត្រីនៅក្នុងស្រែបានដែរ ។

## ប្រភពធនធានសម្រាប់ចិញ្ចឹមត្រីក្នុងស្រែ

- មានចំណេះដឹងក្នុងការចិញ្ចឹមត្រី
- មានកម្លាំងពលកម្មក្នុងការថែទាំស្រែចិញ្ចឹមត្រី
- មានស្រែជាប់ផ្ទះងាយស្រួលគ្រប់គ្រង និងទឹកគ្រប់គ្រាន់រយៈពេល ៦ ខែ
- មានកូនត្រីពូជដាក់ចិញ្ចឹម
- មានកាកសំណល់កសិដ្ឋាន ឬ ប្រភពធនធានកសិដ្ឋានបន្ថែមដូចជា ជីលាមកសត្វ និងកន្ទក់ជាដើមន។

## ១. លក្ខណៈស្រែ

### ក. ការជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រី

ដើម្បីងាយស្រួលក្នុងការចិញ្ចឹមត្រីក្នុងស្រែ ស្រែគួរជ្រើសរើសទីតាំងសមស្រប ដូចខាងក្រោម៖

❐ នៅជិតប្រភពទឹក

❐ នៅជិតផ្ទះងាយស្រួលគ្រប់គ្រង។ ក្នុងករណីស្រែនៅឆ្ងាយពីផ្ទះវិញ យើងក៏អាចចិញ្ចឹមត្រីបានដែរ គ្រាន់តែលំបាកក្នុងការគ្រប់គ្រងប៉ុណ្ណោះ

❐ ជាប្រភេទស្រែជម្រៅតែមិនលិចទឹកជំនន់នៅរដូវវស្សា

❐ ជ្រើសរើសស្រែដែលមានគុណភាពដីល្អ ទឹកមិនភ្លាវ ឬ មិនជូ និងមិនសូវជ្រាបទឹក (ដក់ទឹកបានយូរ) ។

### ខ. លក្ខណៈស្រែចិញ្ចឹមត្រី

❐ ស្រែចិញ្ចឹមត្រីមានទំហំប៉ុនណាក៏អាចចិញ្ចឹមត្រីបានដែរ តែគួរមានពីទំហំ ១០០ ម៉ែត្រការ៉េឡើងទៅ

❐ ស្រែដែលមានទំហំធំល្មម ធ្វើឱ្យងាយស្រួលក្នុងការគ្រប់គ្រង និងសមស្របដល់ការចិញ្ចឹមត្រីបានធំធាត់

❐ ក្នុងស្រែត្រូវជីកជាប្រឡាយ ឬ កូនស្រះសម្រាប់ជាជម្រកត្រីនៅពេលមានកម្ដៅថ្ងៃ និងងាយស្រួលក្នុងការប្រមូលផលត្រី

❐ ស្រែត្រូវមានទឹកជម្រៅសមស្របពី ០.៣ ម៉ែត្រ ទៅ ០.៥ ម៉ែត្រ

❐ ស្រែត្រូវមានភ្លឺខ្ពស់ និងមាំល្អ ដើម្បីការពារទឹកលិចស្រែ

❐ គួរដាំស្មៅនៅតាមភ្លឺស្រែ ដើម្បីកាត់បន្ថយការហូរច្រោះ

❐ បាតស្រែត្រូវរាបស្មើរ ហើយមានជម្រាលទៅជ្រុងម្ខាង ដើម្បីងាយស្រួលពង្រើង និងប្រមូលផលត្រី

❐ នៅតាមភ្លឺស្រែគួរបង្កប់បំពង់ សម្រាប់បង្ហូរទឹកចេញពីស្រះនៅពេលមានភ្លៀងធ្លាក់ច្រើន ។



*ប្រព័ន្ធប្រឡាយក្នុងស្រែចិញ្ចឹមត្រី*

## គ. របៀបជីកជម្រកត្រីក្នុងស្រែ

ដើម្បីឱ្យការចិញ្ចឹមត្រីដំណើរការបានល្អ និងទទួលបានទិន្នផលត្រី និងស្រូវកាន់តែខ្ពស់នោះ យើងត្រូវរៀបចំក្នុងស្រែយ៉ាងណាឱ្យមានជាជម្រកសម្រាប់ត្រីរស់នៅក្នុងទឹកជ្រៅ និងដើម្បីងាយស្រួលប្រមូលផល ។ ដូចនេះយើងត្រូវរៀបចំជាប្រព័ន្ធប្រឡាយ ឬ ស្រះនៅក្នុងស្រែ ដូចរូបភាពបង្ហាញខាងក្រោមឱ្យបានសមស្របទៅនិងលក្ខណៈជីវសាស្ត្ររបស់ត្រីដែលអាចឱ្យវារស់នៅ និងលូតលាស់ធំធាត់បានល្អ ។ប្រព័ន្ធស្រែចិញ្ចឹមត្រីឬជម្រកត្រីក្នុងស្រែត្រូវរៀបចំដូចខាងក្រោមនេះ

## គ.១ លក្ខណៈប្រព័ន្ធស្រែចិញ្ចឹមត្រី






*ការរៀបចំប្រព័ន្ធស្រែចិញ្ចឹមត្រី*

**គ.២ ភ្លឺស្រែ**

ត្រូវរៀបចំភ្លឺស្រែឱ្យបានរឹងមាំល្អ ដូចខាងក្រោម៖

❒ ទំហំទទឹងខ្នងភ្លឺស្រែ : ១ ទៅ ២ ម៉ែត្រ

❒ កម្ពស់ភ្លឺស្រែពី : ០.៥ ទៅ ០.៦ ម៉ែត្រ

❒ ភ្លឺស្រែត្រូវមានកម្ពស់ខ្ពស់ជាងកម្ពស់ផ្ទៃទឹកក្នុងស្រែដែលខ្ពស់បំផុតពី : ២០ ទៅ ៣០ សង់ទីម៉ែត្រ ។

***អត្ថប្រយោជន៍នៃភ្លឺស្រែ***

❒ ការពារត្រីចេញទៅក្រៅស្រែ

❒ រក្សាការពារទឹកនៅក្នុងស្រែ

❒ នៅលើខ្នងភ្លឺស្រែអាចដាំបន្លែផ្សេងៗបានដូចជា : ននោង ឪឡឹក ល្ពៅ ម្ទេស ជី ស្លឹកគ្រៃ និងដាំណាំមានប្រយោជន៍ផ្សេងៗទៀត... ។




*មុខកាត់ទទឹងប្រព័ន្ធស្រែចិញ្ចឹមត្រី*

## គ.៣ ប្រព័ន្ធប្រឡាយក្នុងស្រែ

- ប្រព័ន្ធប្រឡាយគួរឃ្លាតចេញពីភ្លឺស្រែចម្ងាយ ០.៥ ម៉ែត្រ ដើម្បីចៀសវាងការបាក់ដីភ្លឺស្រែចូលប្រឡាយ
- រៀបចំប្រព័ន្ធប្រឡាយឱ្យមានទំហំមាត់ពីលើ ២ ទៅ ៤ ម៉ែត្រ
- រៀបចំស្តារបាតប្រព័ន្ធប្រឡាយឱ្យមានទំហំពី ១ ទៅ ១.៥ ម៉ែត្រ

- ជីកជម្រៅប្រព័ន្ធប្រឡាយពី 0.៨ ទៅ ១.0 ម៉ែត្រ
- គួររៀបចំក្រឡាផ្ទៃប្រព័ន្ធប្រឡាយសរុបពី ១៥ ទៅ ២០ ភាគរយ នៃក្រឡាផ្ទៃដីស្រែសរុប ។

**អត្ថប្រយោជន៍នៃប្រព័ន្ធប្រឡាយ**



*ការរៀបចំប្រព័ន្ធប្រឡាយក្នុងស្រែ*

- សម្រាប់បំប៉នកូនត្រីតូចៗក្នុងអំឡុងពេលកំពុងភ្ជួររាស់ដីស្រែ និងកំពុងស្ទូងរួច
- ជាជម្រកសម្រាប់ត្រីជ្រកកោននៅពេលថ្ងៃក្តៅ
- បង្កលក្ខណៈងាយស្រួលដល់ការប្រមូលផលត្រីនៅពេលសម្រកទឹកចេញពីស្រែ
- និងជាប្រយោជន៍ដល់ការយកទឹកសម្រាប់ស្រោចស្រពដំណាំនៅលើភ្លឺស្រែ ។

**គ.៤ ទ្វារទឹក**

- ស្រែនីមួយៗគួរបង្កើតឱ្យមានទ្វាទឹក ឬ បង្កប់បំពង់ទឹកចំនួនពី ១ ទៅ ២ កន្លែង
- ទ្វាទឹកទាំងនោះ អាចធ្វើពីស៊ីម៉ង់ត៍ និងទុយោជ័រ... ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

**អត្ថប្រយោជន៍នៃទ្វាទឹក**

- ❒ សម្រាប់បើកទឹកបញ្ចូលទៅក្នុងស្រែ
- ❒ សម្រាប់បញ្ចេញ ឬ បញ្ចូលទឹកនៅក្នុងស្រែ ក្នុងករណីចាំបាច់ដូចជា នៅពេលត្រីពុល ពេលច្រូតកាត់ប្រមូលផលស្រូវ និងប្រមូលផលត្រី ។

## ២. ការរៀបចំស្រែមុនពេលដាក់ត្រីចិញ្ចឹម

### ក. ការប្រើប្រាស់កំបោរ

មុនពេលដាក់ត្រីចិញ្ចឹម ១ សប្តាហ៏ យើងត្រូវរៀបចំប្រព័ន្ធប្រឡាយឱ្យបានល្អ ដូចរបៀបខាងក្រោម ដើម្បីកំចាត់ចោលនូវរាល់សត្វចង្រៃ ដែលមានផលប៉ះពាល់ដល់ត្រី និងពពួកមេរោគមួយចំនួន ។

- ❒ បូមទឹកពង្រើងចេញពីប្រឡាយ រួចបាចកំបោរសក្នុងបរិមាណពី ១០ ទៅ ១៥ គីឡូក្រាម,១០០ ម៉ែត្រការ៉េនៃផ្ទៃប្រឡាយ
- ❒ បន្ទាប់ពីបាចកំបោររួច ត្រូវហាលពន្លឺថ្ងៃរយៈពេលពី ២ ទៅ ៣ ថ្ងៃ
- ❒ ករណីគុណភាពទឹកមានជាតិជូរនោះធ្វើឱ្យកម្រិតប៉េហាស់ (pH) ទាបជាង ៥ ដូច្នេះយើងត្រូវបង្កើតបន្ថែមបរិមាណកំបោរសទ្វេដង ប្រមាណពី ២០ ទៅ ៣០ គីឡូក្រាម ,១០០ម៉ែត្រការ៉េនៃផ្ទៃប្រឡាយ ។

## ៦. ការប្រើប្រាស់ជី

❒ បន្ទាប់ពីបាចកំបោរស និងហាលពន្លឺថ្ងៃរយៈពេលពី ២ ទៅ ៣ ថ្ងៃ រួចយើងប្រើជី ។ ប្រភេទជីដែលកសិករអាចប្រើបានល្អ និងមិនចាំបាច់ចំណាយថវិការ គឺជីលាមកសត្វ បរិមាណដែលត្រូវប្រើប្រាស់ពី ២៥ ទៅ ៤0 គីឡូក្រាម ១00មម៉ែត្រការ៉េ នៃផ្ទៃប្រឡាយ រួចបញ្ចូលទឹកជម្រៅពី 0.១ ទៅ 0.៤ ម៉ែត្រ ហើយហាលពន្លឺថ្ងៃរយៈពេលពី ២ ទៅ ៣ ថ្ងៃ ទើបបញ្ចូលទឹកបង្គ្រប់ (ជម្រៅ 0.៨ ម៉ែត្រ) ។

❒ ជីលាមកសត្វដែលអាចប្រើប្រាស់បានរួមមានដូចជា: គោ ជ្រូក មាន់ ទា ។ល ។

❒ ការបាចជីលាមកសត្វជាប្រយោជន៏ដល់ការជួយបន្សាបជាតិជូរផង និងជួយបង្កើនបរិមាណចំណើធម្មជាតិឱ្យកាន់ច្រើនដល់ត្រីស៊ុ ខណៈពេលដែលទើបលែងចូលប្រឡាយដំបូង ។

## គ. ការរៀបចំស្រែ មុនពេលដាក់កូនត្រីចិញ្ចឹម

### គ.១ កម្រិតទឹកក្នុងស្រែ

❒ គួររក្សាទុកទឹកទាបបំផុតនៅក្នុងប្រឡាយ 0.៨ ម៉ែត្រ ពីព្រោះថា ករណីកម្រិតទឹកទាបជាងនេះអាចបណ្តាលឱ្យត្រីពុល ឬ ងាប់បាននៅពេលថ្ងៃក្តៅខ្លាំង

❒ កម្រិតទឹកក្នុងស្រែត្រូវបង្កើនបន្ថែមជាបណ្តើរៗឱ្យកាន់តែជ្រៅ ស្របពេលជាមួយនិងការលូតលាស់របស់ស្រូវនឹងត្រីកាន់តែធំ ដូចបានបង្ហាញតាមរយៈរូបភាពខាងក្រោមៈ



*ដំណាក់កាលទើបនិងស្ងួតរួច ( មិនទាន់ដាក់កូនត្រីចិញ្ចឹម)*



*ដំណាក់ការសន្ទងបែកគុម្ព ( អាចដាក់កូនត្រីចិញ្ចឹមបាន*

## គ.២ ការត្រួតពិនិត្យគុណភាពទឹក

គួរធ្វើការត្រួតពិនិត្យគុណភាពទឹកមុនដាក់ត្រីចិញ្ចឹម ព្រោះថាបើចំណើគុណភាពទឹកក្នុងស្រែ ឬ ប្រឡាយមានរស-ជាតិជូរ ឬភ្លាវ នោះយើងមិនអាចធ្វើការចិញ្ចឹមត្រីបានទេ។ ដូចច្នេះ មុនពេលដាក់ត្រីចិញ្ចឹម យើងត្រូវធ្វើការត្រួតពិនិត្យគុណ-ភាពទឹកជាមុនសិន ដូចបានជម្រាបជូនវិធីសាស្រ្តសាមញ្ញៗតាមបែបលក្ខណៈគ្រួសារខាងក្រោមនេះ :

❒ ជាបឋម សាកល្បងភ្លក់គុណភាពទឹកនៅក្នុងស្រែ ឬប្រឡាយ បើករណីសង្កេតមើលឃើញថា មានរសជាតិជូរ ឬ ភ្លាវនោះបញ្ជាក់ថាមិនល្អសម្រាប់ការចិញ្ចឹមត្រីទេ

❒ ម្យ៉ាងទៀត យើងអាចដឹងបានពីគុណភាពទឹក ដោយគ្រាន់តែស្ដោះទឹកមាត់ស៊ីស្លាម្លូទៅលើផ្ទៃទឹក បើសង្កេតឃើញថា នៅតែរក្សាពណ៌ក្រហមដដែរនោះបញ្ជាក់ថា គុណភាពទឹកល្អសម្រាប់ការចិញ្ចឹមត្រី។ តែផ្ទុយទៅវិញករណីទឹកប្រែពណ៌ពីក្រហមទៅជាពណ៌ខ្មៅនោះបញ្ជាក់ថា ទឹកមានជាតិជូរ ឬ ភ្លាវ ហើយមិនអាចចិញ្ចឹមត្រីបានទេ ។ ករណីនេះយើងចាំបាច់ត្រូវធ្វើការរៀបចំកែប្រែគុណភាពទឹកអោយបានល្អ គ្មានជាតិជូរ ឬ ភ្លាវតាមរយៈកាប្រើប្រាស់កំបោរ និងជីលាមកសត្វ ជាកត្តាសំខាន់ដូចបានបង្ហាញជូនលម្អិតខាងលើ។

## ៣. ការដាក់កូនត្រីចិញ្ចឹម

### ក. ប្រភេទត្រីជ្រើសរើសដាក់ចិញ្ចឹម

ជាប្រភេទត្រីដែលមានលក្ខណៈ ជីវសាស្ត្រសមស្របទៅ និង លក្ខណៈស្រែ ពោលគឺជាប្រភេទត្រីមានការលូតលាស់លឿនក្នុងការចិញ្ចឹមរយៈពេលខ្លីចន្លោះពីការស្ទូងរួចរហូតដល់ពេលច្រូតកាត់ប្រមូលផលស្រូវ និងជាប្រភេទត្រីធន់ទៅនិង លក្ខខណ្ឌទឹករាក់នៅក្នុងស្រែ ព្រមទាំងអាចស៊ីចំណីធម្មជាតិដែលមានស្រាប់នៅក្នុងស្រែ។ លើសពីនេះទៀត ក៏ជាប្រភេទត្រីមានតម្លៃសេដ្ឋកិច្ចខ្ពស់នៅលើទីផ្សារដែរ ។

ប្រភេទត្រីទាំងនេះរួមមានៈ ត្រីឆ្ពិន ត្រីកន្ធរ កង្កុង ត្រីទីឡាព្យ៉ា ត្រីកាបសាមញ្ញ ឬ ត្រីកាបឥណ្ឌា ។ល ។



ត្រីឆ្ពិន



ត្រីកាបសាមញ្ញ



ត្រីកន្ធរ



ត្រីម្រឹហ្គាល



ត្រីទីឡាព្យ៉ា



បង្កង

## ៩. ចំនួន និងទំហំកូនត្រីដាក់ចិញ្ចឹម

ចំនួនកូនត្រីដែលត្រូវដាក់ចិញ្ចឹមនៅក្នុងប្រព័ន្ធស្រែ គឺជាកត្តាមួយដ៏សំខាន់ដែលទាក់ទងទៅនិងលក្ខខណ្ឌជីវិតរស់នៅរបស់ត្រីដូចជា កត្តាគុណភាពទឹក ចំណីធម្មជាតិ និងការលូតលាស់ធំធាត់។ ដូចបានជម្រាបជូននៅខាងដើមរួចមកហើយថាត្រីសម្រាប់ចិញ្ចឹមនៅក្នុងស្រែជាប្រភេទត្រីដែលមានចរិតស៊ីចំណីធម្មជាតិមានស្រាប់នៅក្នុងស្រែ ដូចនេះយើងមិនអាចដាក់កូនត្រីចិញ្ចឹមច្រើនក្បាលក្នុង ១ ម៉ែត្រការ៉េបានទេ។ យើងអាចដាក់កូនត្រីចិញ្ចឹមបាននូវកម្រិតដង់ស៊ីតេទាបចន្លោះពី ១ ទៅ ២ ក្បាល,ម$^{២}$ នៃក្រឡាផ្ទៃសរុបទាំងស្រែ និងប្រឡាយ ។

ម្យ៉ាងទៀត ដើម្បីចិញ្ចឹមត្រីក្នុងស្រែទទួលបានជោគជ័យ កូនត្រីដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ និងមានទំហំធំប្រ-វែងពី ៥ ទៅ ៦ សង់ទីម៉ែត្រ ឬ ៣ ថ្នាំងថៃ ដើម្បីឱ្យកូនត្រីគេចផុតពីសត្រូវ ដែលធ្វើឱ្យកូនត្រីមានអត្រារស់ច្រើន និងធ្វើឱ្យកូនត្រីមានការលូតលាស់ធំធាត់ឆាប់រហ័ស ។

តាមលទ្ធផលទទួលបានពីការអនុវត្តជាក់ស្តែង នៅតាមបណ្តាប្រទេសជិតខាង ក៏ដូចនៅប្រទេសកម្ពុជា ប្រភេទនិងចំនួនកូនត្រីដាក់ចិញ្ចឹម ដូចក្នុងតារាងខាងក្រោម ៖

តារាងបរិមាណកូនត្រីដាក់ចិញ្ចឹមតាមប្រភេទត្រីនីមួយៗ

| ល.រ | ប្រភេទត្រី | ទំហំកូនត្រី | ត្រីដាក់ចិញ្ចឹម | បរិមាណកូនត្រីដាក់ចិញ្ចឹម |
|---|---|---|---|---|
| ១ | ទីឡាព្យ៉ា | ៤-៦ សង់ទីម៉ែត្រ | ២០-៤០ ភាគរយ | ១ ទៅ ២ ក្បាល/ម$^{២}$ |
| ២ | ឆ្ពិន | ៤-៦ សង់ទីម៉ែត្រ | ៤០-៥០ ភាគរយ | |
| ៣ | កន្ធរ ឬ បង្កង | ៣-៥ សង់ទីមែត្រ | ៥-១០ ភាគរយ | |
| ៤ | កាបសាមញ្ញ ឬ កាបឥណ្ឌា | ៦-៨ សង់ទីម៉ែត្រ | ១០-២០ ភាគរយ | |

**គ. ពេលវេលាដាក់កូនត្រីចិញ្ចឹម**

ជាទូទៅនៅប្រទេសកម្ពុជាយើងកសិករចាប់ផ្ដើមចិញ្ចឹមត្រីក្នុងស្រែនៅរដូវវស្សា នៅពេលមានភ្លៀងធ្លាក់គ្រប់គ្រាន់ល្មមសមស្របនៅតាមវាលស្រែ។ ម្យ៉ាងទៀតយើងអាចលែងកូនត្រីចូលស្រែចិញ្ចឹមត្រីបាន ក្រោយពេលស្ទូងរួចរយៈពេលពី ១០ ទៅ ១៥ ថ្ងៃ ឬ ជាការប្រសើរបំផុតក្រោយពេលសន្ទូងបែកគុម្ពនៅថ្ងៃទី ២០ ទៅ ២៥ ដើម្បីចៀសវាងកូនត្រីស៊ីពន្លកស្រូវទើបស្ទូងរួច ។

និយាយរួម យើងអាចកំណត់ពេលវេលាលែងកូនត្រីបានច្បាស់លាស់អាស្រ័យដោយ ៖

- ❒ មានប្រភពទឹកគ្រប់គ្រាន់ក្នុងប្រឡាយ និងក្នុងស្រែ
- ❒ ទឹកក្នុងប្រឡាយ និងក្នុងស្រែមានពណ៌បៃតងខ្ចី
- ❒ ប្រភពកូនត្រីពូជអាចរកទិញបាននៅក្នុងតំបន់របស់ខ្លួន និងទិញពីកន្លែងដទៃទៀត ។

**ឃ. ការដឹកជញ្ជូនកូនត្រី**

ជាទូទៅ កូនត្រីពូជអាចរកទិញពីស្ថានីយ៍រដ្ឋ ឬ ពីកសិដ្ឋានផលិតកូនត្រីឯកជននានាដែលមាននៅក្នុងតំបន់។ របៀបដឹកជញ្ជូនកូនត្រីក្នុងមេរៀននេះ ដូចគ្នានឹងរបៀបដឹកជញ្ជូនកូនត្រីក្នុងមេរៀនបច្ចេកទេសចិញ្ចឹមត្រីក្នុងស្រះ ដែលបានរៀបរាប់ខាងក្រោម ។

**ង. របៀបលែងកូនត្រី**

ក្រោយពេលដឹកជញ្ជូនមិនគួរលែងកូនត្រីពូជចូលប្រឡាយ ឬស្រែភ្លាមៗនោះទេ ចៀសវាងត្រីពុល ឬ អាចងាប់។ ដូចច្នេះ គួររក្សាកូនត្រីពូជនៅកន្លែងណាដែលត្រជាក់មួយរយៈពេលខ្លីជាមុនសិន បន្ទាប់មកធ្វើការលែងដោយសន្សឹមៗរយៈពេលពី ១៥ ទៅ ២០នាទី ដើម្បីប្រយោជន៍ដល់កូនត្រីមានការបន្សាំទៅនឹងមជ្ឈដ្ឋានទឹកថ្មីនៅក្នុងប្រឡាយ ស្រះ ឬ ស្រែ។





*សកម្មភាពលែងកូនត្រីចូលស្រែដែលបានរៀបចំរួចល្អហើយ*

## ៤. ការដាក់ជីបន្ថែមក្រោយពេលដាក់ត្រីចិញ្ចឹម

ការប្រើប្រាស់ជីបន្ថែម ក្រោយពេកដាក់ត្រីចិញ្ចឹមក្នុងស្រែ មានសារៈសំខាន់ដែលចាំបាច់ត្រូវអនុវត្ត ដើម្បីឱ្យការចិញ្ចឹមត្រីបានជោគជ័យ ។ ត្រីចិញ្ចឹមមានការលូតលាស់លឿន ដោយសារការដាក់ជីបន្ថែមបានធ្វើឱ្យក្នុងស្រែសម្បូរចំណីធម្មជាតិ ដែលជាចំណីយ៉ាងសំខាន់សម្រាប់ត្រី ។ ម្យ៉ាងទៀត ការប្រើជីបន្ថែមក្រោយពេលដាក់ត្រីចិញ្ចឹមមានសារៈប្រយោជន៍មិនត្រឹមតែជួយបង្កើនចំណីធម្មជាតិសំរាប់ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ប្រយោជន៍ដល់ការលូតលាស់ដើមស្រូវផងដែរ ។ ជាទូទៅការប្រើប្រាស់ជីបន្ថែម យើងត្រូវអនុវត្តវិធីសាស្ត្រដូចគ្នានឹងការប្រើជីបន្ថែមក្នុងការចិញ្ចឹមត្រីស្រះដែលបានរៀបរាប់ក្នុងមេរៀនខាងលើ ។

## ៥. ការផ្តល់ចំណី

**ចំពោះប្រភេទត្រីស៊ីចំណីធម្មជាតិចម្រុះ** ៖ ត្រូវដាក់ជីលាមកសត្វបន្ថែមជាប្រចាំនៅក្នុងប្រព័ន្ធប្រឡាយ បើករណី យើងឃើញថា ទឹកក្នុងស្រែប្រែពណ៌ពីថ្លាបៃតងខ្ចីទៅជាល្អក់។ ការដាក់ជីលាមកសត្វបន្ថែមនេះ គឺដើម្បីបង្កើនចំណីធម្មជាតិ សម្រាប់ឱ្យត្រីស៊ី។ របៀបប្រើប្រាស់ជីបន្ថែម ត្រូវអនុវត្តដូចគ្នាក្នុងមេរៀនការប្រើជីបន្ថែមក្រោយពេលដាក់កូនត្រី ចិញ្ចឹម។ ក្រោយពីនេះ យើងក៏អាចផ្តល់ចំណីបន្ថែមបានដូចជា ចក កណ្តៀរ ជន្លេន ស្លឹកត្រកួន កន្ទក់ ចុងអង្ករ ដំឡូងមី...។

**ចំពោះប្រភេទត្រីស៊ីរុក្ខជាតិ:** គួរផ្តល់ចំណីបន្ថែមឱ្យត្រីស៊ីជារៀងរាល់ថ្ងៃ។ សមាសធាតុចំណីបន្ថែមត្រូវផ្សំពីពពួក បន្លែផ្សេងៗដូចជា ស្លឹកត្រកួន ស្លឹកស្ពៃ និងសាឡាត់... បរិមាណចំណីដែលត្រូវឱ្យត្រីស៊ីប្រមាណពី ២០ ទៅ ២៥ គីឡូក្រាម សម្រាប់ត្រីទម្ងន់សរុប ១០០ គីឡូក្រាម ដោយផ្តល់ឱ្យត្រីស៊ីចំនួន ០២ ដង ក្នុងមួយថ្ងៃ គឺនៅពេលព្រឹក និងពេលល្ងាច។ ក្រៅពីនេះ យើងក៏អាចផ្តល់ចំណីបន្ថែមផ្សេងៗទៀតដែរ ដែលមានស្រាប់នៅតាមមូលដ្ឋានរបស់កសិករដូចជា កន្ទក់ ចុង អង្ករ កាកសណ្តែកសៀង និងកាកសំណល់ផ្ទះបាយនូវបរិមាណ ១ គីឡូក្រាម ចំណីក្នុងមួយថ្ងៃសម្រាប់ត្រីទម្ងន់សរុប ១០០ គីឡូក្រាម។

## ៦. ការគ្រប់គ្រងស្រែចិញ្ចឹមត្រី

- ជារៀងរាល់ថ្ងៃត្រូវឧស្សាហ៍ព្យាយាមដើរត្រួតពិនិត្យស្រែចិញ្ចឹមត្រីជាប្រចាំថ្ងៃដូចជា កម្រិតកម្ពស់ទឹកក្នុងស្រែ

ទ្វាទឹក ឬ បំពង់បញ្ចេញបញ្ចូលទឹកក្នុងស្រែ និងភ្លឺស្រែដើម្បីជៀសវាងការធ្លុះធ្លាយដែលនាំឱ្យខ្វះទឹកក្នុងស្រែ និងធ្វើឱ្យត្រីងាប់

❐ ក្រោយពេលស្ទូងសន្ទូងរួចរយៈពេលពី ១០ ទៅ ១៥ ថ្ងៃ ឬ ជាការប្រសើរបំផុតក្រោយពេលសន្ទូងបែកគុម្ពនៅថ្ងៃទី ២០ ទៅ ២៥ ត្រូវបញ្ចូលទឹកបន្ថែមចូលស្រែដោយសន្សឹម១ ដើម្បីឱ្យត្រីចូលទៅក្នុងស្រែរកចំណីស៊ីបាន

❐ ករណីសង្កេតឃើញត្រីងើបក្បាលច្រើននៅលើផ្ទៃទឹកពេលព្រឹកព្រលឹមជាញឹកញាប់នោះ ត្រូវផ្លាស់ប្តូរទឹកថ្មីប្រមាណពី ២០ ទៅ ៣០ ភាគរយ

❐ ត្រូវរក្សាជម្រៅទឹកនៅក្នុងស្រែពី ២០ ទៅ ៣០ សង់ទីម៉ែត្រ (២ ទៅ ៣ តឹក) ជានិច្ច ដើម្បីឱ្យត្រីមានការលូតលាស់ល្អ ។

## ៧. ការប្រមូលផល

ជាទូទៅ យើងត្រូវការប្រមូលផលត្រីនៅរដូវប្រាំង ឬ ក្រោយពេលច្រូតកាត់ស្រូវរួច និងគួរធ្វើឡើងស្របពេលនិងតំម្លៃត្រីនៅលើទីផ្សារមានការកើនឡើងខ្ពស់ ។វិធីសាស្ត្រប្រមូលផលត្រីត្រូវគេបានអនុវត្តដូចខាងក្រោមនេះ :

❐ ក្រោយពេលពីចិញ្ចឹមបានរយៈពេលពី ៣ ទៅ ៤ ខែ យើងអាចប្រមូលផលត្រីរំលស់ជាបណ្តើរ១ ដោយប្រើមងនិងអួនអូសចាប់យកត្រីដែលធំ១ពីក្នុងប្រឡាយ និងរក្សាទុកត្រីតូច១ដើម្បីចិញ្ចឹមបន្ត

❐ ប្រមូលផលត្រីសរុប ដោយបូមទឹកសម្រកពីក្នុងស្រែ ដើម្បីឱ្យត្រីចូលក្នុងប្រឡាយ រួចប្រើប្រាស់អួនសម្រាប់អូសចាប់ផលត្រី ។

❒ ការប្រមូលផលត្រីសរុបចុងក្រោយនេះ ក៏យើងអាចប្រមូលតែត្រីធំ និងរក្សាទុកត្រីតូចៗដើម្បីចិញ្ចឹមបន្តនៅក្នុងស្រះ ឬ ប្រឡាយ និងនៅកន្លែងផ្សេងទៀតដែលមានទឹកសម្រាប់ដាក់ត្រីចិញ្ចឹមបន្ត។





*សកម្មភាពប្រមូលផលត្រីសរុបនៅក្នុងស្រែចិញ្ចឹមត្រី*

## ៨. កត្តាសំខាន់ៗដែលត្រូវយកចិត្តទុកដាក់

ការចិញ្ចឹមត្រីក្នុងស្រែ កសិករត្រូវយកចិត្តទុកដាក់នូវសកម្មភាពសំខាន់ៗ ដូចខាងក្រោមនេះ:

❒ ត្រូវចៀសវាងដាក់កូនត្រីចិញ្ចឹមមានទំហំតូច ព្រោះនៅក្នុងស្រែមានត្រីកាច និងសត្វកាចផ្សេងៗទៀតដូចជា កង្កែប ពស់ ជាដើម ។

❒ ហាមប្រើថ្នាំសម្លាប់សត្វល្អិត ឬ លាងសម្ភារៈប្រើប្រាស់ថ្នាំពុលផ្សេងៗក្នុងទឹកស្រែ ព្រោះវាធ្វើឱ្យត្រីងាប់

❒ បើមានស្រែអ្នកជិតខាងប្រើថ្នាំគីមីសម្លាប់ដង្កូវស៊ីស្រូវ យើងត្រូវប្រយ័ត្នកុំឱ្យទឹកក្នុងស្រែនោះហូរចូលក្នុងស្រែយើងដែលយើងកំពុងចិញ្ចឹមត្រី ដោយត្រូវលើកភ្លឺស្រែឱ្យខ្ពស់ និងកុំឱ្យធ្លុះធ្លាយ

❒ កុំប្រើប្រភពទឹកដែលសង្ស័យថាមិនល្អបញ្ចូលស្រែ ព្រោះវាអាចមានជាតិពុលដោយការប្រើប្រាស់ថ្នាំគីមី

❒ មិនត្រូវប្រើប្រភេទជីគីមីគ្រាប់ បាចផ្ទាល់ទៅក្នុងស្រែតែម្តងទេ ព្រោះត្រីអាចចាប់យកគ្រាប់ជីទាំងនោះដោយស្មានថាជាចំណីរបស់វាដែលនិងធ្វើឱ្យវាងាប់ឆាប់រហ័ស

❒ ពេលស្ទូងស្រូវ កសិករគួរស្ទូងឱ្យមានចន្លោះឃ្លាតពីគ្នា ២៥ ទៅ ៣០ សង់ទីម៉ែត្រដើម្បីឱ្យត្រីអាចហែលចេញចូលក្នុងដើមស្រូវរកចំណីស៊ីបាន នៅពេលដើមស្រូវដុះរីកបែកគុម្ព

❒ កុំចិញ្ចឹមប្រភេទត្រីកាបស៊ីស្មៅនៅក្នុងស្រែ ព្រោះវាអាចស៊ីដើមស្រូវរបស់លោកអ្នក ។



## គន្លឹះសំខាន់ៗមួយចំនួនសម្រាប់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

- ការសំអាតស្រះមុនពេលដាក់ត្រីចិញ្ចឹម ជាកត្តាសំខាន់ណាស់ ធ្វើឱ្យការចិញ្ចឹមត្រីរបស់អ្នកទទួលជោគជ័យ
- បើមានត្រីផ្ទក់ ឬ ត្រីរស់តែមួយនៅក្នុងស្រះ វានឹងស៊ីកូនត្រីដែលអ្នកដាក់ចិញ្ចឹមអស់ក្នុងរយៈពេលយ៉ាងខ្លី
- ការដាក់ជីជាប្រចាំដើម្បីឱ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ធ្វើឱ្យត្រីរបស់អ្នកធំធាត់ល្អ
- ពន្លឺថ្ងៃជាកត្តាសំខាន់មួយធ្វើអោយចំណីធម្មជាតិ ឬ បួង់តុងកើតក្នុងស្រះបានល្អក្រោយពេលដាក់ជី
- ការចិញ្ចឹមត្រីក្នុងស្រះមានប្រឡាយភ្ជាប់ទៅស្រែ ជាវិធីមួយដ៏ល្អ ជួយអោយត្រីរបស់អ្នកធំធាត់ឆាប់រហ័ស
- ហើយអ្នកអាចបន្ថយការចំណាយលើការផ្តល់ចំណីទៀតផង ។

## រូបមន្តសំខាន់ៗដែលអ្នកគួរចងចាំ សម្រាប់ការចិញ្ចឹមត្រី

**ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ = ប្រវែងបណ្តោយស្រះជាម៉ែត្រ X ប្រវែងទទឹងស្រះជាម៉ែត្រ**

ឧទាហរណ៍: ស្រះមានប្រវែងបណ្តោយ ១៥ម និងទទឹង ១០ម ។ ផ្ទៃក្រឡាស្រះ = ១៥ម X ១០ម = ១៥០ ម$^{២}$

**បរិមាណកំបោរប្រើប្រាស់ក្នុងស្រះ = ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ X បរិមាណកំបោរប្រើក្នុងមួយរយម៉ែត្រការ៉េ / ១០០**

ឧទាហរណ៍: ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ប្រើកំបោរ ១០គក្រ ក្នុង ១០០ម$^{២}$ ។ បរិមាណកំបោរប្រើប្រាស់ក្នុងស្រះ = ១៥០ X ១០/១០០ = ១៥ គក្រ

**ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រះ= ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ X ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុង ១ម$^{២}$**

ឧទាហរណ៍: ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ដាក់ត្រីចិញ្ចឹម ៣ក្បាល ក្នុង១ម$^{២}$ ។ ចំនួនកូនត្រីដាក់ចិញ្ចឹម = ១៥០ X ៣ = ៤៥០ ក្បាល

**បរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រះ = ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ X បរិមាណជីអ៊ុយរ៉េប្រើក្នុងមួយរយម៉ែត្រការ៉េ / ១០០**

ឧទាហរណ៍: ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ប្រើជីអ៊ុយរ៉េ ៤ខាំ ក្នុង ១០០ម$^{២}$ ។ បរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រះ = ១៥០ X ៤/១០០ = ៦ខាំ

រៀបរៀងដោយ : នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

ឧបត្ថម្ភបោះពុម្ពដោយ : Project Code: 10-PR1-0409

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN

aecid

AIDA

AYUDA, INTERCAMBIO Y DESARROLLO

ព័ត៌មានបន្ថែមសូមទំនាក់ទំនងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
អគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៨៣៥ ទូរស័ព្ទ/ទូរសារ ៨៥៥ ២៣ ៩៩៦ ៣៨០
អ៊ីម៉ែល : chinda77@yahoo.com